# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ សុខ រុំ ភេទស្រី អាយុ៥៨ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ“សមាជិកសហករណ៍នៅសំរោង”**

**ស្រុកកំណើតនៅភូមិតាពោ ឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ**

**សព្វថ្ងៃរស់នៅភូមិចក្រី ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង**

**ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:២៣:១៤**

**៥២ទំព័រ**

ដានីៈ ចឹងមីងដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីងពេញឈ្មោះអីដែរ?

រុំៈ ចា៎?

ដានីៈ ឈ្មោះមីង?

រុំៈ ខ្ញុំឈ្មោះ សុខ រុំ ។

ដានីៈ សុខ រុំណ៎! អាយុប៉ុន្មានហើយមីង?

រុំៈ ៥៨!

ដានីៈ ៥៨ឆ្នាំ! ស្រុកកំណើតនៅភូមិណាដែរ?

រុំៈ ចា៎?

ដានីៈ ស្រុកកំណើតកើតជា?

រុំៈ ស្រុកកណើតនៅឯតាកែវ ។

ដានីៈ ភូមិអីដែរ?

រុំៈ នៅខាងគិរីវង្ស ។

ដានីៈ ខាងស្រុកគិរីវង្ស ។ ស្រុកគិរីវង្ស កាលជំនាន់ពាឆ្នាំ គេហៅស្រុកលេកប៉ុន្មាន?

រុំៈ ចា៎! គេថា១០៩ ។

ដានីៈ ស្រុកគិរីវង្ស ១០៩! តំបន់ប៉ុន្មានកាលហ្នឹង តាកែវ?

រុំៈ តំបន់១៣ ។ ប៉ុនឥឡូវគេប្តូរផ្លាស់ម៉េច ខ្ញុំមិនដែលទៅទេ ។

ដានីៈ បាទ! ១៣ ចុះមីងនៅឃុំកាលហ្នឹង?

រុំៈ នៅឃុំកំពែង ។

ដានីៈ ឃុំកំពែង ចឹងហ្អេ៎! ឃុំកំពែងមកនៅជិតព្រៃកប្បាសវិញចឹងអីអត់ទេ?

រុំៈ ឃុំកំពែងនៅខាង!

ដានីៈ អ៎ូ! បាទៗ! ឃុំកំពែង! ភូមិអី?

រុំៈ ភូមិ តាពៅ ។

ដានីៈ ភូមិតាពៅ ។ តាពៅ ឬក៏តាពង?

រុំៈ តាពៅ!

ដានីៈ តាពៅហ្អេ៎?

អ្នកជិតខាងៈ តាពៅ បាទៗ!

ដានីៈ តាពៅ! សព្វថ្ងៃមីងនៅភូមិអីគេដែរ?

រុំៈ ភូមិចក្រី ។ ឥឡូវគេរំលាយទៅឃុមបារាំងធ្លាក់ ស្រុកភ្នំព្រឹក

ដានីៈ ឃុំអី? ឃុំបារាំងធ្លាក់ហ្អេ៎?

រុំៈ ចា៎ស! ពីមុនភូមិចក្រី ឃុំចក្រី ឥឡូវគេរំលាយទៅឃុំបារាំងធ្លាក់ ។

ដានីៈ ឃុំភ្នំបារាំងធ្លាក់ ស្រុកភ្នំព្រឹកនៅនេះហ៎?

រុំៈ ចា៎ស!

ដានីៈ ខេត្តនេះ?

រុំៈ បាត់ដំបង ។

ដានីៈ បាត់ដំបង ។ មិនមែនបន្ទាយមានជ័យទេ?

រុំៈ អត់ទេ!

ដានីៈ មីងគ្រួសារមីងគាត់ឈ្មោះអីដែរ?

រុំៈ គ្រួសារខ្ញុំឈ្មោះ ឈួន ។

ដានីៈ ឈ្មោះ ឈួន ។ អីឈួនដែរ?

រុំៈ ឈុន ឈួន ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

រុំៈ គាត់បងខ្ញុំបីឆ្នាំ ។

ដានីៈ គាត់បងបីឆ្នាំ អាយុ៥៧ ។ គាត់នៅផ្ទះទេឥឡូវហ្នឹង?

រុំៈ គាត់នៅផ្ទះ ទើបមកពីចម្ការមិញ មិនទាន់មុជទឹកផង ។

ដានីៈ គាត់អ្នកនៅណាដែរ ស្រុកកំណើតគាត់?

រុំៈ គាត់នៅសិង្ហសាហាំង ។

ដានីៈ បាទ! នៅឯណាដែរ?

អ្នកជិតខាងៈ សិង្ហសាហាំង!

ដានីៈ នៅស្វាយ?

រុំៈ នៅខាងត្បូងស្វាយ ។

ដានីៈ ស្រុកអីគេនៅហ្នឹង?

អ្នកជិតខាងៈ ស្រុកសិរីសោភ័ណ្ឌ ។

ដានីៈ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យយើងហ្នឹង ។

អ្នកជិតខាងៈ បាទៗ! បាត់ដំបងអតីត ។

ដានីៈ ចុះមីងជួបគ្នាពីកាល?

រុំៈ ជួបគ្នាកាលឆ្នាំ ន៉ែ៨១ ។

អ្នកជិតខាងៈ គាត់ស្គាល់ ឡៃ វីរៈ ដែរ?

រុំៈ គាត់ស្គាល់តា! គាត់នៅទាហាន ។

អ្នកជិតខាងៈ ទាហានវាយខាងខ្មែរក្រហម ។

ដានីៈ ចុះមីង ឪពុកម្ដាយមីងគាត់ឈ្មោះអីដែរ?

រុំៈ ឪពុកម្ដាយខ្ញុំ គាត់ស្លាប់អស់ហើយ ។

ដានីៈ ឪពុកឈ្មោះអីដែរ?

រុំៈ ឪពុកឪស្លាប់តាំងពីខ្ញុំបាន៨ខែ ដឹងឈ្មោះអី?

ដានីៈ អ៊ូ! តាំងពីមីងនៅតូចៗម៉្លេះ?

រុំៈ ចា៎! ដល់ម្ដាយទើបតែស្លាប់បានពីឆ្នាំនេះ ។ ឈ្មោះ យាយសៀង ។

ដានីៈ ម្ដាយឈ្មោះ យាយសៀង?

រុំៈ ចា៎!

ដានីៈ ហើយមីងបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

រុំៈ បងប្អូនបង្កើត៣នាក់ ។

ដានីៈ បីនាក់?

រុំៈ ចា៎!

ដានីៈ មីងពៅគេ?

វុំៈ ខ្ញុំកណ្តាល!

ដានីៈ ចុះមីងថា គាត់ស្លាប់តាំងពីអាយុ! ឪពុកមីងគាត់ស្លាប់តាំងពីអាយុប៉ុន្មានឆ្នាំ?

វុំៈ នែ៎ខ្ញុំបាន៨ខែ! ប៉ុនដល់ក្រោយទៀត បានម៉ែខ្ញុំមានអី!

ដានីៈ អ្ហូ! គាត់មានគ្រួសារក្រោយទៀតហ៎?

វុំៈ ចា៎ៗ!

ដានីៈ ហ្ហូ! ចឹងមីងមានបងប្អូនបីនាក់?

វុំៈ ចា៎! តែប៉ុណ្ណឹង។

ដានីៈ បីនាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

វុំៈ ទាំងបី ស្រីទាំងបី?

ដានីៈ ស្រីទាំងបីនាក់! មីងកូនទី២?

វុំៈ ចា៎!

ដានីៈ ចុះមីង កាលពីក្មេងៗ បានរៀនសូត្រអីដល់ណាដែរ?

វុំៈ រៀនអី បើអត់បានរៀនផង។

ដានីៈ អត់បានរៀនទេចឹង?

វុំៈ រៀនកាលសម័យ រៀននៅក្រោមដើម គុម្ពឬស្សីអី យន្តហោះទម្លាក់បាញ់អី ពុំបានរៀនទេ។

ដានីៈ ហ្ហូ! ចឹងកាលហ្នឹងហ្អេ៎?

វុំៈ ចា៎!

ដានីៈ ដល់ពេល!

វុំៈ សម័យលន នល់ កាលហ្នឹង។

ដានីៈ ចេះអានចេះសរសេរទេ?

វុំៈ ចា៎! កាលហ្នឹងចេះ ដល់ពេលឥឡូវចាស់ហើយ វាភ្លេចវាភ្លាំងអស់ហើយ។

ដានីៈ ភ្លេចអស់ហើយណ៎?

វុំៈ ចា៎! បានមើលរួចខ្លះ?

ដានីៈ មើលរួចខ្លះ។ បានមើលរួចហ្នឹងតាំងពីក្មេងៗ ឬក៏ធំហើយមានរៀនសូត្រអីក្រោយទៀត?

វុំៈ ខ្ញុំកាលឆ្នាំ៧៧ គេមកឲ្យនៅឯស្វាយ នៅឯបាត់ដំបងនែក! ដល់គេឲ្យមកបង្រៀនក្មេង បង្រៀនអីតូចៗទៅ ចេះតែរៀបតិចៗទៅ។

ដានីៈ កាលហ្នឹងមីងអត់ចេះទេ តែគេឲ្យមីងទៅបង្រៀនក្មេងៗ?

រុំៈ	ចាំ! បង្រៀនតិចៗ ទៅចេះតែចេះទៅ!

ដានីៈ	អូ! ចុះអត់បានរៀនសូត្រមីងនៅធ្វើអីទៅកាលពីក្មេងៗ?

រុំៈ	កាលខ្ញុំពីក្មេងៗ ខ្ញុំ កាលពីចេញពីផ្ទះមក គេឲ្យនៅដេញចាប ។

ដានីៈ	អត់ទេ! កាលនៅពីក្មេងៗ កាលហ្នឹងកាលនៅរៀន កាលនោះក្មេងអត់នៅជាមួយឪពុកម្ដាយទេ?

រុំៈ	ខ្ញុំនៅជាមួយឪពុកម្ដាយ ប៉ុនខ្ញុំចេញពីឪពុកម្ដាយខ្ញុំអាយុ៩ឆ្នាំ ខ្ញុំមកនៅឯកងកុមារ ។

ដានីៈ	នៅជាមួយ ឪពុកបានត្រឹមតែអាយុ៩ឆ្នាំទេ?

រុំៈ	ចាំ! ដល់ខ្ញុំចេញមក មកនៅឯកងកុមារ ។ គេដាក់កុមារកំព្រាកាលហ្នឹង ។ កងកុមារកំព្រា នៅបាន៤ឆ្នាំ បានខ្ញុំ ។

ដានីៈ	ឆ្នាំណាបានមីងមកនៅកងកុមារ?

រុំៈ	ចាំ!

ដានីៈ	ឆ្នាំណា?

រុំៈ	ដល់ឆ្នាំ៧៥ ។

ដានីៈ	ឆ្នាំ៧៥! មក?

រុំៈ	ឆ្នាំ៧៦,៧៧!

ដានីៈ	នៅកុមារកំព្រា!

រុំៈ	ហ្នឹងហើយ ដល់ពេលឆ្នាំ៧៧ខ្ញុំមកបាត់ដំបងនេះ គេឲ្យមកនៅឯបាត់ដំបង ។

អ្នកជិតខាងៈ មកជាមួយតាជាត ។

រុំៈ	ចាំ! ខ្ញុំមកមុនតាជាតទៀត តាជាតមកក្រោយខ្ញុំទេ ។ ខ្ញុំកាលនោះមាននារី៥០០នាក់ ហ៊ូ! កុមារា៥០០នាក់ កុមារី៥០០រយនាក់ មកបាត់ដំបងហ្នឹង ។

ដានីៈ	ចឹងពីឆ្នាំ៧៥ ពេលដែលរំដោះបានទីក្រុងភ្នំពេញ កាលហ្នឹងមីងចូលក្នុងកុមារកំព្រា?

រុំៈ	ចាំ! ខ្ញុំនៅកុមារកំព្រា ។

ដានីៈ	នៅឯណាកុមារកំព្រាហ្នឹង?

រុំៈ	កុមារកំព្រាហ្នឹង នៅទន្លេបាសាក់ ទៅជិតនៅព្រំប្រទល់យួនហ្នឹង ។

ដានីៈ	អូ! នៅស្រុកគិរីវង្សហ្នឹងដែរ ។

រុំៈ	ចាំ! នៅព្រំប្រទល់យួនហ្នឹងម៉ង ។

ដានីៈ	គេហៅអីគេ ស្រុកហ្នឹង?

រុំៈ នៅទន្លេបាសាក់ដែរ ពូឯងអត់ស្គាល់ទន្លេបាសាក់ដែរទេ?

ដានីៈ ទន្លេបាសាក់?

រុំៈ ចាំ! កុំនិយាយមិនស្គាល់ ។

ដានីៈ ទន្លេបាសាក់ពីភ្នំពេញទៅអ៎!

រុំៈ ហឺ! ទន្លេបាសាក់ជិតឯស្រុកយួនហ្នឹងណា ។

ដានីៈ អ៎ូ! ចឹងហ៎!

រុំៈ សួរតាជាតទៅ តាជាតក៏គាត់ស្គាល់ដែរ ។ គាត់នៅវាយហ្នឹងដែរ កងតាជាត កាលហ្នឹងធ្វើសង្គ្រាមជាមួយយួន ប្រយិតប្រយង់ ប្រទាញប្រទង់ជាមួយយួនកាលហ្នឹង ។

ដានីៈ ទន្លេបាសាក់ក្នុងស្រុកគីរីវង្ស ។

រុំៈ ហឺ! ចេញពីទន្លេបាសាក់មកហើយ មកនៅឯកំពង់អំពិល ។

ដានីៈ ចឹងកាលហ្នឹងនៅកុមារនេះ គ្នាច្រើនទេ?

រុំៈ នៅគ្នាច្រើន គ្នាច្រើនលើកទំនប់ លើកប្រឡាយ ។

ដានីៈ ហ៎ូចឹង!

រុំៈ ល្ងាចថ្មើហ្នឹងឲ្យដេញចាប ដល់ពេលថ្ងៃនែ៎!

ដានីៈ ចឹងកាលហ្នឹងមីង ថាមីងទើបអាយុ៩ឆ្នាំហ្នឹង!

រុំៈ ហឺ! ពេញដេញចាបម៉ង!

ដានីៈ ៩ ឆ្នាំហ្នឹង?

រុំៈ អត់ទេ៩ឆ្នាំ ខ្ញុំចេញពីផ្ទះមក ។

ដានីៈ ៩ឆ្នាំចេញពីផ្ទះមក មកនៅឯណា?

រុំៈ នៅឯទន្លេបាសាក់

ដានីៈ ចឹង៩ឆ្នាំ ឆ្នាំ៧៥មកដេញចាបហើយ?

រុំៈ ចាំ!

ដានីៈ ធំជាងនេះតិចហ្នឹង?

រុំៈ នេះទើបតែ៣ឆ្នាំហ្នឹង ធំជាងនេះតិចចេះតែនិយាយ ៩ឆ្នាំនោះអាដើរ ។

ដានីៈ ប៉ុនហ្នឹង ចេះដេញចាប?

រុំៈ ដេញហ៊ោៗ ឆ្នូងឆ្លើយជាមួយយួនគោះដួង យួនគេព្រែកមួយចំហៀង យើងមួយចំហៀងទៅ ឈរដេញចាបឆ្លងឆ្លើយដាក់គ្នា ហ៊ោហ៊ុំដាក់គ្នា ។

ដានី៖ អត់ឈ្មោះគ្នា?

រុំ៖ ចុះកូនយួន! ហើយដល់វាចេះតែលើកដៃសុំត្រកួន យើងចេះតែបេះបោះឲ្យវាទៅ, វាអត់!

ដានី៖ ឆ្លងទន្លេ ឬយ៉ាងម៉េច អាទន្លេបាសាក់ហ្នឹង?

រុំ៖ ឆ្លងទន្លេវា អាខាងនោះ ដីយួន អាខាងដីយើង ។

ដានី៖ ទន្លេធំ ឬតូច ទន្លេបាសាក់ហ្នឹងខ្ញុំអត់ស្គាល់?

រុំ៖ ទន្លេហ្នឹងធំ ប៉ុនដល់មានដៃវារាងស្ងួច ដូចអូរព្រំដែនយើងចឹងណា មានរីក មានស្ងួចចឹងទៅ ហើយទឹកល្អល្អាចចឹងទៅ ។

ដានី៖ ហើយកាលហ្នឹងមីងមានអាយុ៩ឆ្នាំ កាលហ្នឹងមានចាំថាគេ មានគ្នាច្រើនមានដឹកទំនប់ប្រឡាយ

រុំ៖ ច្រើន ខ្ញុំអាយុ៩ឆ្នាំកាលហ្នឹង ដល់ពេលអាយុ១២ឆ្នាំ ខ្ញុំនៅហ្នឹង ហ្នឹងគេឲ្យឡើងនែក យុវនារីណា ចូលកងយុវនារីហើយ ១២, ១៣ឆ្នាំចូលយុវនារីហើយ ជិទន់ហើយ ។

ដានី៖ ចឹងមនុស្សច្រើនចឹង ពីណាគេប្រធាន?

រុំ៖ ចាំ!

ដានី៖ នៅកន្លែងកុមារកំព្រាហ្នឹង?

រុំ៖ កន្លែងគ្រប់គ្រងតឡូវគេយក វាយចោលអស់ហើយ ។

ដានី៖ ពីណាគេ?

រុំ៖ ធ្វើបាបគេពេក ៗ ដូចថាពេលដែលប្រជាជនហ្នឹងឧបត្ថម្ភអង្ករ ឧបត្ថម្ភអំបិល ឧបត្ថម្ភប្រហុក យកទម្លាក់ទឹកព្រែកអស់ហើយណាស់ ខោអាវសម្លៀកបំពាក់អត់ឲ្យក្មេងស្លៀកពាក់ ហើយភ្លៀងមករងារញាក់ញ័រ កាប់អារស្មៅកុម្មុយនីសហ្នឹង យកទៅធ្វើដីបូលប្រក់ទៅ កៅស៊ូក៏មិនឲ្យ ហើយយកទៅបណ្តែតទឹកទៅ បើអំបិលវិញឲ្យគ្នាស៊ីសាប មិនឲ្យគ្នាស៊ីទេ គ្នានៅអង្គុយញាក់ញ័រ ទម្រាំគេដឹង ស្រាវជ្រាវរកឃើញទៅពួកយួនវាឲ្យការណ៍មក ឃើញសុទ្ធតែការុងអំបិល អង្រឹង ខោខ្លី ស្មើរ ៗ ហ្នឹងយកទៅបណ្តែតទឹក យកទៅកប់ភក់នៅអាមាត់ប្រេក ប្រមុះជ្រូកយួនហ្នឹង អាព្រែកយួន យួនឲ្យរបាការណ៍មកហ្នឹង ដឹងចាប់វាយចោល កាលហ្នឹងមិនទាន់យកទៅវាយចោល គ្រាន់តែចាប់ឃើញបណ្តើរទៅមុខ ខ្ញុំនៅប៉ុន្តែខ្ញុំ ចាប់ពួកមេ ៗ អស់ទៅគេឲ្យឡើងមកខាងនេះ ។

ដានី៖ មេខាងកុមារកំព្រាហ្នឹង?

រុំ៖ ចាំ!

ដានី៖ ឈ្មោះអីទៅ?

រ៉ុះ	ហ៊ឺ(សើច) មិនចង់ប្រាប់ឈ្មោះទេ ។

ដានីៈ	ចុះគាត់ស្លាប់ហើយ គ្រាន់តែប្រាប់ឈ្មោះ!

រ៉ុះ	គាត់ស្លាប់ហើយ ប៉ុនគ្រាន់តែនឹកឃើញវាដូចនៅថ្មីៗខ្ញុំខ្ជិល ។

អ្នកជិតខាងៈ គាត់ស្លាប់ហើយ ប្រាប់ទៅវាមានទោស្អី អនុស្សាវរីយ៍បើមិនប្រាប់ម៉េចដឹង ។

រ៉ុះ	ព្រោះបងប្អូនគេនៅជិតៗហ្នឹង ខ្ញុំម៉េចហ៊ានប្រាប់ ។

ដានីៈ	ហ៊ូ! ចុះនៅគិរីវង្សពីណាគេនៅគណៈស្រុក?

រ៉ុះ	ចា៎!

ដានីៈ	គណៈស្រុកគិរីវង្ស?

រ៉ុះ	គណៈស្រុកគិរីវង្សហ្នឹងតាអីទេ ម៉ែខ្ញុំបានគាត់ស្គាល់ កាលគាត់មកលេងខ្ញុំកាលគាត់នៅរស់ ស្គាល់តា ខ្ញុំក្មេងអស់ហើយកាលហ្នឹងនៅស្ទើរៗដែរពុំសូវចាំ ចាំតែប្រធានកង ប្រធានភូមិ ក្រុមយើង ។

ដានីៈ	ប្រធានភូមិ ប្រធានក្រុមហ្នឹងឈ្មោះអីដែរ?

រ៉ុះ	នែ៎! បើប្រធានកងវរសេនាធំឈ្មោះ បងរ៉េត ១០៥ ហើយកងតូចហ្នឹងនែ៎ឈ្មោះបងអីទេ បងខ្សៀន ។

ដានីៈ	គាត់នៅដែរ?

រ៉ុះ	គេចាប់ទៅយកបាត់ ។

ដានីៈ	គេចាប់ទៅ!

រ៉ុះ	គេចាប់ពុំដឹងថាទៅណាឯណី អត់ដឹងដែរ ប៉ុនថាបងប្អូនកូនចៅមកនេះគាត់សួរដែរ បាត់គាត់ថា បាត់យូរហើយ ប៉ុនខ្ញុំដឹងតែទាំងអស់ ។

ដានីៈ	ចឹងៗ អង្ករអី អំបិលអីគេអត់យកទៅទម្លាក់ទឹក?

រ៉ុះ	អត់ទេ! បើថាមួយឆ្នាំងខ្ទះ មួយកង៥០ចឹង មួយកង៥០គ្នា៥០,៦០នាក់ចឹង ដាក់តែអង្ករបី កំប៉ុងទេ ហាន់ប្រូគគ្រួនហើយព្រលិតហ្នឹងលាយគ្នាហូប ។

ដានីៈ	ចុះគេយកអង្ករទៅណាទៅ?

រ៉ុះ	គេយកទៅពន្លិចបណ្តែតទឹកអស់ទៅណា គាហូបអំបិលគេពុំឲ្យហូបផងណា ហូបសាបហ្នឹង ។

ដានីៈ	គេខឹងក្មេងៗរឿងអីបានជាគេយកអង្ករ?

រ៉ុះ	អត់ទេ! តាមមើលក្បត់ម៉ង មិនថាក្មេងៗទេ កងនារីយុវជនក៏អីចឹងដែរ ។ បើថាកងទ័ពហ្នឹងគេ បានហូបឆ្អែត ។

ដានីៈ ដល់ពេលហើយខាងគណៈអីគេមកចាប់ទៅ?

រុំៈ បែបគេស្រាវជ្រាវ បានគេមកឃើញចាប់ហៅទៅតែម្តង ហៅដើរឃើញៗនៅមុខហៅទៅ គេដកគ្រឿងសម្ភារៈកាលគេបើកឲ្យតាំងពីកង់ តាំងពីវ៉ាដ្យូទាំងអីទាំងអស់ហ្នឹង គេដកយកទាំងអស់ហ្នឹង ។ គ្រាន់តែឃើញគេដកយកយើងអ្នកនេះ យើងចេះតែមើល យើងពុំហ៊ានថាអីទេ ចុះកាលហ្នឹងខ្លាចងាប់ណាស់ណា៎ បើយើងមិនប្រយត្ន័ពាក្យសំដីយើងងាប់ យកអត់ដឹងខ្លួនទេ យកចេញអត់ដឹងខ្លួន យកទៅសម្លាប់ចោលអត់អំពើ ។

ដានីៈ ធ្លាប់ឃើញគេសម្លាប់ទេ?

រុំៈ ឃើញយើងចេះរាងចាលហើយខ្លាច ទាល់សព្វថ្ងៃហ្នឹង ។

ដានីៈ ឃើញនៅត្រង់ណា?

រុំៈ ហ្នឹងក៏គេនិយាយស្អីៗ ក៏ខ្ញុំសួរហ៊ានខ្ញុំខ្លាច បើឃើញនៅហ្នឹងភ្នែកដូចបាក់ហើយ ។

ដានីៈ ឃើញភ្នែកហ្នឹង ឃើញនៅឯណា?

រុំៈ ហ៊ឹម! សម្លាប់ច្រើនណាស់ សម្លាប់បណ្តើរទាំងខ្សែហ្នឹងណា ដើរងាប់ហ្នឹង ។ បើថាកូនក្មេងៗប៉ុណ្ណឹងងាប់ហើយ ដាក់ចំពុះទង់ពីក្រោមចាប់ក្រវែងចូល... ។

ដានីៈ កាលជំនាន់មីងនៅឯគិរីវង្សហ្នឹង?

រុំៈ ចា៎! នៅទន្លេបាសាក់ ។

ដានីៈ កាលមីងនៅទន្លេបាសាក់ហ្នឹង?

រុំៈ ឃើញសាហាវណាស់ ។

ដានីៈ ទន្លេបាសាក់ហ្នឹងនៅស្រុកគិរីវង្សដែរ?

រុំៈ ក្នុងស្រុកព្រំប្រទល់យួនតែម្តង ឃើញសាហាវ ។

ដានីៈ ឃើញកន្លែងគេសម្លាប់អី ចាំកន្លែងគេសម្លាប់?

រុំៈ មាន!

ដានីៈ នៅទន្លេបាសាក់ហ្នឹងតែម្តង?

រុំៈ ចា៎ស! ភូមិអំពិល ភូមិយោលហ្នឹងងាប់ហើយ ។

ដានីៈ កំពង់អំពិល កំពង់យោល?

រុំៈ វាយងាប់សម្លាប់ ទម្លាប់ឲ្យត្រី ឲ្យកំពតវាស៊ី ហើយមិនសូវហាននិយាយទេខ្ញុំខ្លាច បានខ្ញុំចងចាំ បានម៉ែខ្ញុំថាកូនអើយ ទឹកម៉ែថ្ងៃបានគេមកជាមួយកូនឯងក្នុងមួយភូមិ គ្នា១០នាក់ នៅសល់កូនឯងតែពីរនាក់ទេ ។

ដានី៖ សល់ពីណា?

វ៉ុ៖ សល់មួយទៀត នៅឯនេះណ៎ នៅ៣២ ។

ដានី៖ នៅឯណា៣២?

វ៉ុ៖ នៅឯរោង៣២ ។

ដានី៖ ភូមិអី?

វ៉ុ៖ នៅគេហៅ៣២ហ្នឹងតែម្តង ។

ដានី៖ នៅ៣២ ។

វ៉ុ៖ អត់ដល់សាស្តាទេ ។

អ្នកជិតខាង៖ កំណាត់ផ្លូវលេខ៩ ។

វ៉ុ៖ ហ៊ឺម! នៅនេះនេជាប់ហ្វូស៤០៤នេះតិច ។

ដានី៖ ឈ្មោះ រូ?

វ៉ុ៖ ឈ្មោះ អារូ ។

ដានី៖ ស្រី ឬប្រុស ។

វ៉ុ៖ ប្រុស ។

ដានី៖ អាយុដំណាលគ្នាដែរ?

វ៉ុ៖ អាយុស្រករគ្នាហ្នឹង ។

ដានី៖ ចុះមីង មានប្រសាសន៍មិញថា នៅអាយុ៩ឆ្នាំ ដល់១២ឆ្នាំ គេអត់ឲ្យចូលកងនារី ។

វ៉ុ៖ កងនារី ។

ដានី៖ កងនារីនៅបុសាក់ដដែរ?

វ៉ុ៖ នៅកងនារីចេញពីទន្លេបាសាក់យើង ឡើងមកនៅទីនេះ ។

ដានី៖ បើងអាយុ១២ឆ្នាំចូលនារី ចេញពីទន្លេបាសាក់មកនៅទីណា?

វ៉ុ៖ ខ្ញុំមកនៅបាត់ដំបង គេមកឲ្យនៅបាត់ដំបង ។

ដានី៖ ឆ្នាំណាហ្នឹង?

វ៉ុ៖ ឆ្នាំនែ៎ក ឆ្នាំ៧៧ ។

ដានី៖ ៧៧ ខែប៉ុន្មាន?

វ៉ុ៖ មើលខែដកស្ទូង ខែ៨ហេ៎ ខែ៦ហេ៎! ខែរលីម១ខ្ញុំមូលចងក្បិនទៃស្ទូងដកសំណាបជី ប្រជាជនឲ្យមូលដើងខោខ្វចឈ្លើងតាមនោះ ។

ដានី៖ ខែ៦ ខែចូលឆ្នាំហើយ?

រ៉ុំ៖ ចា៎!

ដានី៖ ខែទើបតែភ្លៀង ទើបចាប់ភ្លៀង។

រ៉ុំ៖ ខែ៦ហ្នឹងឯង, ខែ៦ មកស្ទូង មកដល់ប្រជាជនចុះស្ទូងព្រាត។

ដានី៖ កាលហ្នឹងគេអ៎យ៉ាងម៉េច ម៉េចបានមីងដឹងថាម៉េច គេបញ្ជូនមីងពីគិរីវង្សរហូតមកដល់បាត់ដំបង?

រ៉ុំ៖ បញ្ជូនហ្នឹងអត់ដឹងដែរ ឡានអ៎ កាលហ្នឹងជិះរទេះភ្លើង មកដល់តាកែវ ដេកតាកែវពីរយប់នៅរៀនសូត្រហ្នឹងហើយ ចេញពីតាកែវមកដល់ភ្នំពេញ ដល់ភ្នំពេញគេឲ្យនាំដើរលេងដើរអីនោះបីយប់។ ចេញពីភ្នំមក មកស្វាយហ្នឹង ម៉ោង១១យប់ ពីភ្នំពេញមក។

ដានី៖ ចុះមីងពីគិរីវង្សដែលមកដល់តាកែវ កាលហ្នឹងមកប៉ុន្មាននាក់?

រ៉ុំ៖ ចា៎?

ដានី៖ ចេញពីគិរីវង្សមក មកប៉ុន្មាននាក់?

រ៉ុំ៖ គ្នា៥០០នាក់នារី។

ដានី៖ ចេញពីគិរីវង្សមកទាំងអស់?

រ៉ុំ៖ ចា៎!

ដានី៖ ទាំង៥០០នាក់ហ្នឹងចេញពីគិរីវង្ស ៥០០នាក់អាយុដំណាលៗមីងដែរ ឬក៏ចាស់ជាង?

រ៉ុំ៖ គេមក ខ្លះគេរៀងចំនាស់ ជាងខ្ញុំទៅ អាខ្លះគេបងខ្ញុំទៅ កងហា កងក្រុមគេមកៗ។ ខ្ញុំកំពុងដេញចាបគេទៅហៅមក។

ដានី៖ ទើបតែអាយុ១២ឆ្នាំហ្នឹង?

រ៉ុំ៖ ចា៎! ខ្ញុំនៅគោះផ្ដៅចប នៅឯកណ្ដាលចម្ការ ខ្ញុំអត់ដឹងគេហៅមកៗ។

ដានី៖ បានគេហៅមកហ្នឹង បានចូលទៅលាឪពុកម្ដាយ បានទៅចូលទៅប្រាប់?

រ៉ុំ៖ អត់បានលា គេមិនឲ្យទៅ។ សរសេរសំបុត្រជិតមកដល់តាកែវហើយហ្នឹង ហើយបាចសំបុត្រប្រជាជនកំពង់ស្ទូងស្រូវ បាចសំបុត្រឲ្យប្រជាជនរើស បញ្ជូនទៅឲ្យម៉ែយើង ប៉ុនទៅដល់មិនដល់អត់ដឹង។

ដានី៖ នៅតូចហើយអត់បានរៀនផង សរសេរសំបុត្រយ៉ាងម៉េច?

រ៉ុំ៖ ហីបងៗខ្ញុំ គេស្រលាញ់ខ្ញុំណាស់ បងៗកងហាគេស្រលាញ់ខ្ញុំណាស់ អត់ចង់ឲ្យបែកទេ ចុះខ្ញុំគេប្រើឲ្យធ្វើអីខ្ញុំធ្វើហ្នឹង ធ្វើ គេប្រើតែម្ដង ធ្វើតែម្ដង មិនដែលបាននៅផ្ទះទេ។ ហើយធម្មតាគេ

ចូលចិត្តនឹងយើង គេប្រើយើងបាន យើងធ្វើហ្នឹង គេស្រលាញ់យើងតែម្ដង ។ និយាយតាមត្រង់គេស្រលាញ់ណាស់ ។

ដានី៖ ក្នុងនារី៥០០នាក់ ដែលដឹកនាំមក ពីណាឈ្មោះអីទៅអ្នកដែលដឹកនាំក្នុង៥០០នាក់ហ្នឹង?

រ៉ុំ៖ តា១៥គាត់ឲ្យមក ។

ដានី៖ តាម៉ុក ។

រ៉ុំ៖ តាម៉ុក ។

ដានី៖ គាត់ឲ្យមកទាំង៥០០នាក់មក ក្នុងចំនោម៥០០នាក់ពីណាគេ?

រ៉ុំ៖ យកមកដល់ស្វាយហើយបំបែក ។

ដានី៖ ប៉ុន្តែខ្ញុំចង់ដឹង ពេលដឹកហ៎?

រ៉ុំ៖ ខ្ញុំអត់ស្គាល់ ។

ដានី៖ អត់ស្គាល់ទេណ៎?

រ៉ុំ៖ ខ្ញុំអត់ស្គាល់ ហ្នឹងហើយ! ចុះគេនៅកងខុសគ្នា ។

ដានី៖ ប៉ុន្តែតាម៉ុកគាត់ចុះទៅដល់គិរីវង្សដែលអត់ទេ?

រ៉ុំ៖ ទៅដល់! ទៅដល់ហ្នឹង ។

ដានី៖ ដល់ហ្នឹងថាត្រូវយកនារី៥០០នាក់ ។

រ៉ុំ៖ រើសតាមឈ្មោះ តាមឈ្មោះ តាមកង ។ គេរើសអ្នកប្រវត្តិរាងគ្រាន់ៗ ។

ដានី៖ តាម៉ុកគាត់ធ្វើ គ្រប់គ្រងនៅគិរីវង្សដែរ?

រ៉ុំ៖ គ្រប់គ្រងខាងនារីយុវជន តែមួយអាទិត្យអីហ្នឹង ៣ថ្ងៃហ្នឹងឃើញគាត់ទៅដល់ ឃើញចុះពីឡានដូចឃើញថានារីៗលីស្រូវលីអីដាក់ នែ៎ដាក់ដាក់អី តាម៉ុកទៅដល់ ទាញដំបងដាក់ប្រុសៗវត់ពេញហ្នឹង អាណាឲ្យនារីៗលីបាវស្រូវ យើងប្រុសយើងនៅឈរបើតបារី ។ ដាក់វត់ដេញដកនារីៗយកចេញអត់ឲ្យលីទេ ។

ដានី៖ គាត់យកអីវាយ?

រ៉ុំ៖ ឈើរច្រត់គាត់ហ្នឹង វាយប្រុសៗវត់ ប្រើនារី នរណាអ្នកបញ្ជារឲ្យប្រើហ្នឹង ។ នារីៗគ្មានខាងលីសែងចឹងទេ ។

ដានី៖ ក្រែងប្អូនថ្លៃគាត់តានៅលើ គ្រប់គ្រងនៅឯហ្នឹង?

រ៉ុំ៖ ចា៎!

ដានី៖ ក្រែងប្អូនថ្លៃគាត់តាអី?

រ៉ុះ	ប្អូនថ្លៃគាត់ហ្នឹង ប៉ុនដូចបន្តទៅទៀត មិនមែនតែគាត់ផ្ទាល់ ត១គេប្រើយើងត១ ហើយយើងចេះតែ។

ដានីៈ	គាត់អត់ដែលស្តីឲ្យប្អូនថ្លៃគាត់ទេ?

រ៉ុះ	ចា៎!

ដានីៈ	នៅគីរីវង្សហ្នឹង?

រ៉ុះ	គាត់ស្តីតើ គាត់ធ្វើខុសហ្នឹងស្តី។

ដានីៈ	ដែលឮគាត់ស្តីឲ្យទេ?

រ៉ុះ	ស្តី! ត្រូវវាយ វាយផស។

ដានីៈ	វាយ?

រ៉ុះ	យុវជនក្រៅហ្នឹងក៏ចឹង។

ដានីៈ	យាយថាវាយនរណាគេ ថាគេវាយ វាយផស។

រ៉ុះ	ហ៊ឺ! វាយថាដូច ថាកុំឲ្យប្រើនារីចឹងទៅណា! វាយអ្នកយុវជនផ្សេងក៏គាត់វាយ ដូចថាគាត់បើកឡានទៅដល់ គាត់មើលពីចំងាយថា បើប្រុស១វានៅឈរ យុវជនគេនៅឈរនារី១លីទៅដល់ដាក់ផស១។

ដានីៈ	ប៉ុនក្រែងកាលហ្នឹងប្អូនថ្លៃគាត់ហ្នឹងក្រែងតាទិតហ្នឹងក្រែងស្រុកនៅគីរីវង្សហ្នឹង?

រ៉ុះ	ធ្វើគណៈស្រុកប៉ុនគាត់មានសួរចុះដាប់ណា គាត់ច្រើនចុះខាងប្រជាជន។

ដានីៈ	ហើយកាលហ្នឹងមីងស្គាល់តាទិតទេ?

រ៉ុះ	ចា៎!

ដានីៈ	ស្គាល់តាទិតទេ?

រ៉ុះ	ខ្ញុំស្គាល់កាល ម៉ែខ្ញុំគាត់ទៅលេង គាត់ទៅលបលេង គាត់ទៅ៣យប់បីថ្ងៃ គាត់ទៅវិញអន្សមវេចនំយកផ្ញើរខ្ញុំ។ ខ្ញុំសូមមកលេងគេមិនឲ្យមកលេង គេថាចាំបុណ្យ១៧មករាចាំឲ្យអូនឯងទៅលេង។ ល្ងាចស្មាហ្នឹងយំនឹកម៉ែ នឹកបងប្អូន ដល់គេថាអូនឯងកុំយំអីចាំបុណ្យ ១៧មករាចាំទៅលេង ដល់ពេលបុណ្យ អត់ឲ្យទៅលេងទេ។

ដានីៈ	បុណ្យ១៧មេសាអី?

រ៉ុះ	អើ!១៧មេសា ហ្នឹងហើយ។ ដល់ហើយអត់ព្រមឲ្យលេង អត់មកលេង ដល់ម៉ែគាត់នឹកពេកឮតាមត១គេ គាត់មកលេងម្តង ឃើញម៉ែរឹតតែនឹក យប់ឡើងរត់។

ដានីៈ	រត់ទៅណា?

រុំៈ រត់ទៅផ្ទះ តែរត់រកផ្លូវអត់ឃើញ ហើយក៏ចុះទៅព្រៃកស្រុកឃួនស្នានេះ យប់ឡើងឃើញសៗខ្ញុំស្មានតែដី វាលស្រែប្រាំងដល់ចុះទៅជ្រៅទៅៗ រត់មកវិញគេចាប់បាន រត់ហែងគេដេញវាយជុំវិញផ្ទះគេហ្នឹងទៅ មេគេហ្នឹងទៅ។ ១០,២០ជុំ បានគេឲ្យចូលកងមកធ្វើការទៀត ហ៊ូ! វេទនាណាស់ ។

រុំៈ ចុះមីងថាស្គាល់តាទិតហ្នឹង ស្គាល់ពេលណា?

ដានីៈ និយាយមិញថារត់?

រុំៈ ពេលណាបើយើងទៅធ្វើការបងៗកងគាត់ថានោះន៎ែក តាទិតមកហើយកុំមាត់! ចេះតែមាត់ទំប្រឹងតែធ្វើទៅ ពេលធំៗចូលមកចេះតែជួយប្រាប់គ្នា ហ្នឹងហើយយើងក្លាចគេ ក្រោមដឹកនាំយើងហ៊ានឈប់ ។

ដានីៈ កាលហ្នឹងមីងស្គាល់មុខច្បាស់ទេ ឃើញមុខគាត់ទេ?

រុំៈ ហ៊ូ! ឥឡូវភ្លេចបាត់អស់ហើយ ។

ដានីៈ កាលជំនាន់ហ្នឹង?

រុំៈ តែប្អូនខ្ញុំ ខ្ញុំភ្លេចមកលេងខ្ញុំមិនស្គាល់ផង ។

ដានីៈ ប្រពន្ធគាត់ប្អូនតាម៉ុកបង្កើតហេ៎?

រុំៈ ប្អូនបង្កើតហេ៎ ។

ដានីៈ ស្គាល់ឈ្មោះហេ៎! ស្គាល់ឈ្មោះយាយហ្នឹងទេ? ស្គាល់ឈ្មោះគាត់ទេ កូនប្អូនប្រពន្ធគាត់?

រុំៈ ហេ៎អត់ស្គាល់ទេ ។

ដានីៈ ហើយចឹងមីងកាលខែ៦ ឆ្នាំ៧៧ ខែ៦ហ្នឹង តាម៉ុក គាត់ទៅរើសនារី៥០០នាក់ពីគិរីវង្សហ្នឹងមក?

រុំៈ គិរីវង្សហ្នឹងមក ។

ដានីៈ ចឹងគាត់យកមកដល់ មកដល់?

រុំៈ មកដល់ស្វាយយើងហ្នឹង គាត់បំបែកជាក្រុម ។

ដានីៈ បាទ! មកដល់ខាងតាកែវហ្នឹងត្រូវរៀនសូត្រ២ថ្ងៃ?

រុំៈ រៀនសូត្រ២ថ្ងៃ ។

ដានីៈ រៀនពីអីខ្លះទៅ?

រុំៈ រៀនពីយើងមក សភាពការណ៍វាម៉េចៗ យើងមកចុះជាមួយប្រជាជន ធ្វើការថាដូច ដូចថាសហករណ៍ណាគ្នាអត់មានស្អីចឹងទៅអត់ឲ្យគ្នា បំបែកជាតាមក្រុម តាមកង តាមភូមិចឹងទៅចុះ

ប្រុសក្នុងមួយភូមិ ក្នុងមួយភូមិដូចថានារីគ្នា៨នាក់មួយភូមិ គ្នា៩នាក់មួយភូមិ បំបែកទៅតាមភូមិ ។ ទៅធ្វើការប្រជាជនដេញកាប់ ហ៊ឹម! គេថាយើងអ្នក១៧មេសាចុះមកក្នុងភូមិ ក្នុងឃុំគេហ្ន៎! កាប់សំរប់នារីកាលហ្នឹងច្រើនណាស់ ច្រើនតែសំរប់ពួកស្រែអំបិល ។

ដានី: ចុះមីង?

រ៉ុំ: ខ្ញុំរត់ចូលក្រោមជង្រុក ខ្ញុំតូចខ្ញុំត្បូលត្រង់ណាក៏បានដែរ ។

ដានី: ចុះមីងខែ៦ហ្នឹង ពេលដែរមកដល់តាកែវអើ! តាម៉ុកហ្នឹងគាត់អ្នកបង្រៀន ពីរថ្ងៃហ្នឹងតាម៉ុកគាត់អ្នកបង្រៀនយើង?

រ៉ុំ: តាម៉ុកអត់បង្រៀនទេ មិនដឹង ។

ដានី: ពីណាគេ?

រ៉ុំ: ណាអត់ស្គាល់ ប៉ុនគេខាងអ្នកធ្វើការដឹកនាំមកហ្នឹងឯង ប៉ុនយើងអត់ស្គាល់ទេ ។

ដានី: ដឹកនាំមក?

រ៉ុំ: ចា៎!

ដានី: អត់ដឹងឈ្មោះអីទេ?

រ៉ុំ: អត់ទេ!

ដានី: គេមានបង្រៀនប្រាប់ថាម៉េច ពេលដែលយើងត្រូវគេជ្រើសរើសមក យើងមកពីគិរីវង្សមក៥០០នាក់ មកថាឲ្យយើងទៅនៅឯណា ទៅធ្វើអី?

រ៉ុំ: គេប្រាប់ថា គេឲ្យទៅនៅពាយ្យ័ ។

រ៉ុំ: ឲ្យមកនៅឯពាយ្យ័ មកពាយ្យ័ហើយគេបំបែកតាមសហករណ៍ ។

ដានី: គេមានប្រាប់ថាពាយ្យ័ យ៉ាងម៉េចបានគេជ្រើសរើសយើងឲ្យនៅ?

រ៉ុំ: យើងអត់ហ៊ានសួរគេយ៉ាងម៉េច បានគេបមបែកកមកឲ្យបំបែកមកនៅសហករណ៍ ។

ដានី: គេឲ្យយើងប្រុងប្រយ័ត្នអ៊ីខ្លះ?

រ៉ុំ: ឲ្យប្រុងដែរ ។

ដានី: ថាប្រជាជននៅនេះយ៉ាងម៉េច ក្បត់អីយ៉ាងម៉េច?

រ៉ុំ: ចា៎ស ៗ!

ដានី: បឹងឲ្យយើងប្រុងប្រយ័ត្ន កុំ! ប្រយ័ត្ន ។

រ៉ុះ	គេឲ្យប្រុងប្រយ័ត្នពីរឿងយើងធ្វើការចុះជាមួយគេ ប្រយ័ត្នពាក្យសំដី ហើយយើងថាតាមដានគេ គេបម្រុងធ្វើបាបយើង យើងប្រយ័ត្នខ្លួនកុំឲ្យដើរតែឯង ។ ខ្ញុំថាយើងចង់ដើរទៅណាដើរទៅឯង ដើរប្រុយៗអត់បានទេ ។

ដានី:	គេមានប្រាប់យើងថាឲ្យប្រយ័ត្នប្រយែង គេនិយាយអី យើងយកប្រាប់ខាងប្រធានគេ ។

រ៉ុះ	ហ្នឹងហើយ! ប្រយ័ត្នពាក្យសំដីពាក្យអី និយាយរួមប្រយ័ត្នមួយចប់ គេប្រជុំអប់រំអីចឹង ។

ដានី:	បាទ! ហើយដល់ពេលរៀនសូត្រនៅតាកែវ បានពីរថ្ងៃ អើ! មីងត្រូវបានបញ្ជូនមក ភ្នំពេញទៀត ។

រ៉ុះ	ភ្នំពេញទៀត ។

ដានី:	ទាំង៥០០នាក់ ។

រ៉ុះ	ចាំ! ភ្នំពេញហ្នឹង មក៣ថ្ងៃ ដូចបីថ្ងៃ៣យប់ចូលប្រជុំមួយថ្ងៃ បានគេនាំដើរលេងតាមក្រុម ។

ដានី:	ហើយមកភ្នំពេញបាន៣ថ្ងៃទេ អត់រៀនសូត្រអីទេ?

រ៉ុះ	រៀនមួយថ្ងៃ ។

ដានី:	រៀនមួយថ្ងៃរៀនជាមួយពីណា?

រ៉ុះ	អត់ស្គាល់!

ដានី:	មានជួបខាងតា ប៉ុល ពតអីទ?

រ៉ុះ	មិនដឹងខាងណាអត់ដឹង ។

ដានី:	អត់ដឹងទេណ៎?

រ៉ុះ	អត់បានសួរបានអីគេដងហ្នឹង យើងដឹងតែពីស្តាប់គេ ។

ដានី:	ដឹងតែពីស្តាប់គេ ។ គេរៀន១ថ្ងៃហើយគេជូនដើរលេងត្រង់ណាខ្លះ?

រ៉ុះ	នាំឡានដឹកដើរលេងតាមកន្លែងស្អីស្តេចសោយរាជ្យ ស្តេចស្អីៗ ។

ដានី:	កន្លែងវាំង?

រ៉ុះ	កន្លែងស្អីៗ ភ្នំកូន វត្តព្រះភ្នំវត្តអីហ្នឹង គេនាំដើរលេងទាំងអស់ ។

ដានី:	ហើយដល់ពេលរួចទៅស្នាក់ណោះឯម្តុំណា?

រ៉ុះ	ស្នាក់នៅ គិតទៅស្ពានជ្រោយចង្វារ ខ្ញុំទៅមុជស្ពានជ្រោយចង្វារទឹកហ្នឹងណា ហើយដាក់ពីខាងនេះបេះ ។

ដានី:	ជិតស្ពានជ្រោយចង្វារដែរ?

រ៉ុះ	ចាំ! ដឹងត្រង់ណាទេ ។

ដានីៈ ហើយតាម៉ុក គាត់មានជូនមកទេ?

វ៉ុៈ អត់ឃើញ ។

ដានីៈ អត់ឃើញទេណ៎ ។ ហើយជិះពីតាកែវមកភ្នំពេញ ជិះស៊ីមកជិះឡាន ឬជិះរទេះភ្លើង?

វ៉ុៈ ជិះរទេះភ្លើង ។

ដានីៈ ជិះរទេះភ្លើង! ដល់ពេលមកដល់ទីក្រុងភ្នំពេញគេជូនឡាន គេយកឡានដឹកយើងដើរលេង ឬក៏?

វ៉ុៈ ដើរលេងអាហ្នឹងឡាន ។

ដានីៈ ចុះ៥០០នាក់ឡានដឹកប៉ុន្មានគ្រឿងទៅ?

វ៉ុៈ ហ៊ីឡាន អាឡានទេសចរណ៍គេ មិនចេះតិច ហើយអត់មានហូបបាយទេ ហូបតែនំប័ុងជាមួយ ន៉ែកសម្ងសាច់គោ សាច់ជ្រូក ។

ដានីៈ ចឹងនំប័ុងសុទ្ធតែម្តង?

វ៉ុៈ នំប័ុងសុទ្ធតែម្តង ។

ដានីៈ ឆ្ងាញ់ទេកាលហ្នឹង?

វ៉ុៈ នំប័ុងឡើង ប៉ុនៗនេះ ហូបអត់បាយ ហូបនំប័ុងហ្នឹង ។

ដានីៈ អត់ហូបបាយទៀតទេ?

វ៉ុៈ អត់ហូបបាយទេ! គេអត់ចែកបាយឲ្យផង ។

ដានីៈ តែឆ្អែតអត់ហូបតែនំប័ុង?

វ៉ុៈ យី! ម្នាក់ជីងតែ៥ដើម ។

ដានីៈ ម្នាក់៥ដើម?

វ៉ុៈ ម្នាក់៥ដើម ។

ដានីៈ ហូបអស់ដែរចឹង?

វ៉ុៈ អត់ទេ មានអស់ទេ! ដាក់ហែងទាល់តែ មកដេកនៅហូបនៅស្វាយទៀត ។

អ្នកជិតខាងៈ ចុះមានឃើញប្រជាជនច្រើនអត់នៅឯភ្នំពេញ?

វ៉ុៈ ប្រជាជនអត់មានដូចឥឡូវទេ ។ ឃើញតែកងទ័ពច្រើន នៅភ្នំពេញមានតែកងទ័ព ។

ដានីៈ អត់មានមនុស្សអីដើរ?

វ៉ុៈ មនុស្សនៅកន្លែងរោងចក្រអីគេដែរ ចូលរោងចក្ររោងអីគាត់ដេរហ្នឹងណា ។ មកដល់គេមកដល់ គេប្រជុំឲ្យយើងស្ម័គ្រចិត្តទៅខាងណា ។

ដានីៈ ចុះប៉ុនកាលហ្នឹងមីងទើបតែអាយុ១៧ឆ្នាំហ្នឹង?

រុំៈ ចា៎!

ដានីៈ ទើបតែ១២ឆ្នាំមកពេញហ្នឹង?

រុំៈ ខ្ញុំ១២ឆ្នាំ ១២ឆ្នាំ តាំងពីនៅនេះហ្នឹងមក អាយុ១២ឆ្នាំ ដល់ពេលហើយ ១៣-១៨ឆ្នាំ ខ្ញុំពេញក្រមុំហើយមកនៅឯបាត់ដំបង ។ មកពេញនៅឯបាត់ដំបង ។

ដានីៈ ១៨ឆ្នាំ?

រុំៈ ចា៎! ខ្ញុំមកពេញណោបាត់ដំបង នៅស្វាយ នៅសំរោង ។ ស្គាល់ភូមិសំរោងទេ?

អ្នកជិតខាងៈ នៅជិតស្ទឹងនៅខាងលិច ។

រុំៈ ខ្ញុំនៅភូមិបត់ត្រង់ហ្នឹង ។

អ្នកជិតខាងៈ សាលាក្រហម សំរោងដីរ ។

រុំៈ ចា៎!

ដានីៈ ហើយកាលហ្នឹងមីងនៅពីខែ៦យើងចេញពីភ្នំពេញ យើងមកនៅត្រង់ណាវិញ? ពីភ្នំពេញមកពាយ័ព្យយើងជិះអីមក?

រុំៈ រទះភ្លើង ។

ដានីៈ រទះភ្លើងទាំង៥០០នាក់ហ្នឹង?

រុំៈ ទាំង៥០០នាក់ ជាថ្នាក់ ជិះពីនឹងទៅដល់ឃើញផ្លូវបត់ទៅមើលឃើញក្រោយនោះ កន្ទុយរទះភ្លើងមិនដឹងជាប៉ុន្មាន ។

ដានីៈ សប្បាយអត់មីងកាលយើងជិះរទះភ្លើង?

រុំៈ សប្បាយ! ដេកលក់ចង់អង្រើងនៅលើហ្នឹង ។

ដានីៈ អត់នឹកម្តាយបងប្អូនទេ?

រុំៈ សប្បាយជានឹក ប៉ុណ្ណេះជាដាច់ខាត ជាតស៊ូដាច់ខាត ជាវាយសាប់ត្រង់ណាសាប់ត្រង់ណាត្រង់ទៅ បើមនុស្សច្រើនម៉្លេះៗ ។

ដានីៈ ចឹង?

រុំៈ វាជាយកទៅណា សម្លាប់ឯណាសម្លាប់ទៅ កាលគេជ្រើសរើស ២,៣នាក់ទៅដឹងភ័យបុកពោះ ដឹងគេប្រុងយកទៅណា ដល់ឃើញគ្នាច្រើនសាប់ត្រង់ណាសាប់ទៅលែងគិតហើយ យកដល់ណា ក៏ដល់ទៅ ។

ដានីៈ ឃើញគ្នាច្រើន ។

រុំៈ ចុះសាប់ ត្រង់ណា យើងវាមិនច្បាស់បើគ្នាច្រើន មនុស្សមានតិចឯណា ។

អ្នកជិតខាងៈ ចុះបែស្គាល់មិត្តនារីចាន់ថាអត់?

វុំៈ ថ្មីមិនស្គាល់ បងចាន់ថាហ្នឹង ។

ដានីៈ ចុះមីងមកពីបាត់ដំបងហ្នឹងមានចុះកន្លែងណាទៀតទេ មកឈប់ណា?

វុំៈ ចាំ?

ដានីៈ ហ្វូ! ពីភ្នំពេញហ្នឹងមក រទេះភ្លើងមានឈប់នៅកន្លែងណា?

វុំៈ រហូតមកដល់ស្វាយហីងតែម្តង ។

ដានីៈ ជិះមកស្វាយតែម្តង អត់ឈប់នៅឯបាត់ដំបងទេ?

វុំៈ អត់មានឈប់ទេ ។

ដានីៈ អត់មានឈប់ទេ?

វុំៈ អត់ដឹងបាត់ដំបងបែរទៅណាផង ពាយ័ព្យមក ។ គិតទៅពីភ្នំពេញមករហូតមកដល់ស្វាយហ្នឹង ឡើងម៉ោង១កន្លះ ។

ដានីៈ ខ្ញុំធ្លាប់ជួបយាយថែម គាត់ថាគាត់ជិះរទេះភ្លើងមក មកពីតាកែវដែរតើ មានជួបគ្នាដែរទេ?

វុំៈ យាយថែមហេ៎?

ដានីៈ បាទ!

វុំៈ យាយថែមមកក្រោយខ្ញុំទេ ។

ដានីៈ មកក្រោយចឹងមីងមកមុនគាត់ទៀត?

វុំៈ មកមុនគាត់ ខ្ញុំមកមុន៣ខែ ។

ដានីៈ មកមុនគាត់៣ខែ

វុំៈ ខ្ញុំមកមុន៣ខែ មកមុនតា ជាត, តា ប៉ូហ្នឹង៣ខែ ។

ដានីៈ ហ្វូ! តាប៉ូណា?

វុំៈ តាប៉ូនេះណ៎! យាយអ៊ុត ។

ដានីៈ គាត់មកនៅជាមួយតាជាតដែរ តាប៉ូ?

វុំៈ តាប៉ូ គាត់ធ្វើធំដែរ ។ តា ជាត គាត់ក៏ធំ តាប៉ូគាត់ក៏ធំដែរ តែតាប៉ូគាត់ធំជាងតាជាតមួយជាន់ ។

ដានីៈ តែគាត់នេះហេ៎?

វុំៈ តែគាត់ស្លាប់បាត់ហើយ! តាប៉ូ គាត់ស្លាប់ឆ្នាំទៅ, តាជាតគាត់ស្លាប់ឆ្នាំនេះ តា ប៉ូគាត់ស្លាប់ឆ្នាំទៅ ។

អ្នកជិតខាងៈ ចុះប្រពន្ធគាត់នៅ?

រ៉ុះ ប្រពន្ធគាត់នៅ នោះប្រពន្ធគាត់នៅអន្លុយតុងនោះ ។

ដានីៈ ហើយកាលហ្នឹងមីងមកមុនយាយថែម ។

រ៉ុះ ខ្ញុំមកបីខែ ។

ដានីៈ ខ្ញុំជួបគាត់ គាត់ថាជិះរទេះភ្លើង មកគ្នាច្រើនណាស់ ។

រ៉ុះ ហ្នឹងហើយៗ! យាយថែមគាត់នាំប្រជាជនសុទ្ធមកតែម្តង ។ ខ្ញុំអត់មកប្រជាជនទេ មកនារីយុទ្ធជនតែម្តង មកជាមួយនារីយុទ្ធជនសុទ្ធតែម្តង ។ នារី៥០០ យុវជន៥០០ ទាំងអស់មួយពាន់នាក់ណា ។

ដានីៈ ចុះម៉េចមីងដឹងថាម៉េច មីងមកមុនគាត់៣ខែ ។

រ៉ុះ ទេ!គេឲ្យមកនរណាទៅដឹង ។

ដានីៈ ប៉ុន្តែម៉េចមីងដឹងថា គាត់មកក្រោយមកមីង ។

រ៉ុះ ជីមិនដឹង បើខ្ញុំមកបានបីខែបានដឹងថាប្រជាជនមក១០០០គ្រួសារទៀតហើយ មកតាមក្រោយ គេប្រាប់បានអរតិចបានឃើញគេមកច្រើន ។

ដានីៈ គេប្រាប់ថាប្រជាជនមក១០០០គ្រួសារទៀត មកតាមក្រោយហ្នឹងមានឈ្មោះយាយថែមគាត់មកហ្នឹងដែរ?

រ៉ុះ ឈ្មោះយាយថែមក៏គាត់មក ខ្ញុំទៅស្ពាយនឹងចុះទទួលម៉ែៗប្រជាជនឲ្យទៅ ជួបនៅស្ពាយនឹងឯង ។

ដានីៈ ហ៊ូ! មីងមកទទួលដែលណ៎?

រ៉ុះ មកទទួល! ឲ្យតែនារីស្លៀកខ្មៅពាក់ខ្មៅជិនាន់ហ្នឹង ។

ដានីៈ ដល់ពេលគេឃើង គេមកពីខាងនោះ មកជមួយគ្នាចឹងយើងសប្បាយនែស?

រ៉ុះ ចុះបើបានមកគ្នាច្រើនមិនសប្បាយ បើមកតែឯង ហ៊ូមិនដែលដេកបានទេយប់ ។

អ្នកជិតខាងៈ កាត់បងឯងសិន! ស្គាល់បូ ហើយនឹងមីងមនទេ?

រ៉ុះ មននៅភូមិណា?

អ្នកជិតខាងៈ បូ ហើយនឹងយាយមន?

រ៉ុះ ហ៎! ដូចជាធ្លាប់ឮឈ្មោះប៉ុន្តែបើឃើញប្រហែលជាអាចធ្លាប់ស្គាល់ ។

អ្នកជិតខាងៈ បូកាលនោះធ្វើប្រធានសហករណ៍ ។

រ៉ុះ ហ្នឹងហើយ ។

អ្នកជិតខាងៈ ចុះចាន់ថាមានស្គាល់ទេ?

រ៉ុៈ បើចាន់ថា បានស្គាល់ច្បាស់ ។

អ្នកជិតខាងៈ ចាន់ថាមេខ្ញុំ នារីហើយទាប ។

ដានីៈ បាទ! ហើយ ។

រ៉ុៈ គាត់រៀនស្រដីបន្តិច ។

អ្នកជិតខាងៈ មាឌដូចថែឯងចេះចឹង ។ មេខ្ញុំផ្ទាល់ មេខ្ញុំបង្កើត បូនោះ! នៅជាមួយបូនោះ មនហ្នឹង ។

ដានីៈ ហឹចុះមីង! ដល់ពេលមីងជិះអ៎ ពីភ្នំពេញមកដល់ឈប់ដល់ស្វាយតែម្តង?

រ៉ុៈ ឈប់ស្វាយហ្នឹងចា៎ស!

ដានីៈ ដល់ពេលឈប់នៅស្វាយឈប់នៅត្រង់ណា?

រ៉ុៈ ឈប់នៅស្វាយហ្នឹង ឈប់នៅខាងណាស៊ីងទេ វង្វេងកាលហ្នឹង មួយផ្ទះថ្មគេ ចុះមកដល់យប់ឡើងម៉ោង១ ខ្ញុំមកដល់ដេកមួយសន្ទុះហើយបានគេដាស់ហូបបាយហ្នឹង ហូបទំប៉ុងលើរទេះភ្លើងមកដល់លក់ទៅ បាននារីគេដាំបាយឲ្យគេឡើងហៅនៅលើផ្ទះថ្មពីរជាន់ ។

អ្នកជិតខាងៈ ផ្ទះថ្មហ្នឹង! នៅមាត់ស្ទឹង ។

រ៉ុៈ ហ្នឹងហើយនៅមាត់ស្ទឹងហ្នឹង ព្រលឹមឡើងខ្ញុំទៅមុជទឹកនៅស្ទឹងហ្នឹង ។

ដានីៈ ចុះពីរទេះភ្លើងមក ចុះនៅកន្លែងណា? មកនៅណាទៅ? មកនៅឯស្វាយ ឬក៏មកនៅឯសំរោងម៉ង?

រ៉ុៈ អត់ទេ! នៅស្វាយហ្នឹងបីថ្ងៃ បានគេប្រជុំហើយបានបែកជាកង ជាកំលាំង ។

ដានីៈ ចឹងមកដល់ស្វាយបានបីថ្ងៃសិន?

រ៉ុៈ ចា៎!

ដានីៈ បីថ្ងៃបាននៅកន្លែងណា នៅម្តុំផ្ទះណា?

រ៉ុៈ ផ្ទះម្តុំណា ផ្ទះនឹងផ្ទះខាងស្ពៃគេ បើយើងនៅផ្ទះថ្ម ផ្ទះថ្មបីជាន់ហើយ ឲ្យនារីៗនៅហ្នឹង ហើយដល់គេប្រជុំឲ្យបំបែកតាមនេះទៅ នៅជិតស្ទឹង ប៉ុនមិនដឹងថាជិតស្ទឹងត្រង់ណា ។ ខ្ញុំវង្វេង តែរាល់ថ្ងៃនៅស្វាយក៏ខ្ញុំនៅតែវង្វេង ។

ដានីៈ បាទ! ចឹងមកដល់ស្វាយហ្នឹង ទាំង៩០០នាក់នៅប្រជុំគ្នាទាំងបីថ្ងៃសិន?

រ៉ុៈ ប្រជុំបីថ្ងៃសិន ។

ដានីៈ ពីណាគេប្រជុំ ប្រជុំជាមួយពីណា?

រ៉ុៈ ហ៊ឹម! មិនសូវស្គាល់ទេ ប្រជុំកាលហ្នឹងមិនសូវស្គាល់ទេ បើមុខអាចំណាំបាន ។

ដានីៈ កាលហ្នឹងស្គាល់តារិនទេ?

រ៉ុៈ តារិនក៏ស្គាល់ ។

ដានីៈ កាលហ្នឹងមកប្រជុំ តារិនគាត់មកធ្វើ?

រ៉ុៈ តារិនក៏មកចូលរួមប្រជុំដែរ ។

អ្នកជិតខាងៈ ចុះតាជាល តាត្រក ។

រ៉ុៈ តាជាលក៏មក មកមេៗច្រើនណាស់ ។

អ្នកជិតខាងៈ ចុះតាវ៉ាល់?

រ៉ុៈ តាអីមួយទៀតទេ អាហ្នឹងបានខ្ញុំស្គាល់ច្បាស់ ។

អ្នកជិតខាងៈ តាវៀម?

ដានីៈ តានៅណា គាត់នៅណា? តាចាយ ស្គាល់តាចាយទេ?

រ៉ុៈ ហ្នឹងហើយ! តាចាយ ។

ដានីៈ តាចាយ គាត់អ្នកមកដឹកនាំប្រជុំ?

រ៉ុៈ ចា៎ស!

ដានីៈ កាលហ្នឹងធំជាងគេ?

រ៉ុៈ ចា៎ស! ហ៊ៅមិនដឹងថាណាធំ ណាទៀតទេអត់ដឹង បើអត់ដឹងដែរ ។

ដានីៈ ប៉ុន្តែតាចាយហ្នឹង?

រ៉ុៈ នារីមួយទៀត ។ នារីហ្នឹងក៏ធំដែរ នារីក៏ធំបន្ទាប់ទៀតមានយោបល់អប់រំ ។

ដានីៈ មែនយាយថែមទេ?

រ៉ុៈ ហ៊ុម! លើយាយថែមទេ រាងចំនាស់បន្តិច ឈ្មោះអី?

អ្នកជិតខាងៈ ឈប់ខ្ញុំរកគិតសិន!

ដានីៈ ហើយដល់ពេលប្រជុំបីថ្ងៃហ្នឹង តាចាយគាត់អ្នកដឹកនាំប្រជុំ?

រ៉ុៈ គាត់អ្នកដឹកនាំប្រជុំ បំបែកជាកងជាក្រុម មកតាមសហករណ៍តាមភូមិ ។

ដានីៈ ហើយបំបែកម៉េចខ្លះទៅ មីងចាំទេ?

រ៉ុៈ បំបែកម៉េច! បំបែកមកដឹកដាក់តាមភូមិ តាមឃុំតែម្តង ។

ដានីៈ ចុះមីងមកនៅឯណា?

រ៉ុៈ ខ្ញុំមកនៅឯសំរោង ។

ដានីៈ សំរោងប៉ុន្មាននាក់?

រ៉ុះ ចា៎!

ដានីៈ មកនៅប៉ុន្មាននាក់?

រ៉ុះ មកសំរោង កាលនោះគ្នា៥០នាក់ៗ ដល់បំបែកតាមភូមិ តាមសហករណ៍ បើសហរណ៍ខ្លះគ្នា១២,១៣នាក់ៗ បើអ្នកណារាងតូចៗស្មើរៗ ឲ្យគ្នា១៥នាក់ បើពួកខ្ញុំគ្នា១៥នាក់ៗ

ដានីៈ គ្នា១៥នាក់ មួយសហករណ៍?

រ៉ុះ គ្នា១៥នាក់មកធ្វើសិល្បៈរាំពួកប្រជាជនមើលលន់ៗ

ដានីៈ នៅសំរោងហ្នឹង?

រ៉ុះ ចា៎!

ដានីៈ សំរោងហ្នឹងនៅក្នុងស្រុកមង្គលបុរី?

អ្នកជិតខាងៈ សំរោងស្រុកមង្គលបុរី ឬសំរោងនៅត្រើយខាងលិច សំរោងសាលាក្រហម?

រ៉ុះ សំរោង សាលាក្រហមៗ

ដានីៈ ហ្នឹងសេរីសោភ័ណ្ឌ ឬនៅ?

រ៉ុះ សេរីសោភ័ណ្ឌៗ

ដានីៈ មិនមែននៅក្នុងមង្គលបុរីទេ?

រ៉ុះ ខ្ញុំកាលហ្នឹងជិះកង់ទៅសាលាក្រហមៗ

ដានីៈ អីចឹងសំរោង-សេរីសោភណ្ឌនៅតំបន់៥ទេ?

រ៉ុះ តំបន់៥ទាំងអស់ៗ

ដានីៈ ក្នុងស្រុកសេរីសោភ័ណ្ឌ?

រ៉ុះ ចា៎!

ដានីៈ កាលហ្នឹងតាចាយ គាត់នៅហ្នឹងដែរ? នៅសេរីសោភ័ណ្ឌហ្នឹងដែរ?

រ៉ុះ តាចាយ នៅហ្នឹងៗ

អ្នកជិតខាងៈ នៅផ្ទះក្បឿង ឬផ្ទះអី?

រ៉ុះ ពីណាគេ ខ្ញុំ?

អ្នកជិតខាងៈ តាចាយហ្នឹង?

រ៉ុះ នៅផ្ទះក្បឿងៗ

អ្នកជិតខាងៈ ផ្ទះថ្ម ផ្ទះក្បឿង ត្រូវហើយ ផ្ទះនៅសព្វថ្ងៃតា៎ៗ

ដានីៈ ចុះតារិន គាត់នៅផ្ទះហ្នឹងដែរ?

វ៉ុះ	តាវិន កាលហ្នឹងគាត់ទៅនៅ គាត់បំបែកទៅនៅក្រឡាញ់ ។

ដានីះ	គាត់នៅក្រឡាញ់?

វ៉ុះ	ចា៎ស!

ដានីះ	ក្រឡាញ់ណា?

អ្នកជិតខាងះ	ក្រឡាញ់ យាយថែម កន្លែងភ្នំលាបនោះ ។

ដានីះ	ហ្នឹងគេហៅក្រឡាញ់?

អ្នកជិតខាងះ	ក្រឡាញ់ ខេត្តបាត់ដំបងនោះ ។

ដានីះ	ក្រឡាញ់ទៅខាងសៀមរាបនោះវិញ ។ គាត់ដូរទៅខាងក្រឡាញ់វិញ?

វ៉ុះ	ហ្នឹងហើយ គាត់ទៅខាងហ្នឹង ។

ដានីះ	ហើយកាលហ្នឹងគណៈស្រុកនៅសេរីសោភណ្ឌ?

វ៉ុះ	ខាងណាគណៈស្រុកប្រជាជននេះ? ប្រជាជននៅសំរោង? នៅសេរីសោភ័ណ្ឌ? តាអីគេ តាហ្នឹងគេចាប់បាត់ហើយ ដូចបាត់ខ្លួន ។

អ្នកជិតខាងះ	តាផាត់?

វ៉ុះ	ចា៎ ដូចបាត់ខ្លួន ។

អ្នកជិតខាងះ	ហ៎ូ! តាជាល?

វ៉ុះ	តាជាល ហ្នឹង ។ ពួងងនៅក្រោយក្រែងដឹង ខ្ញុំមកនៅនេះហើយ ។

អ្នកជិតខាងះ	ចាំមើល តាជាល គេសម្លាប់ចោលជាមួយ តាវ៉ាល់ ។

ដានីះ	រួចពីណាគេបន្ទាប់ពីហ្នឹងមកទៀត?

វ៉ុះ	៣នាក់ ។

អ្នកជិតខាងះ	តាជាល និងតាត្រេក, បានដាក់ពួកតាផាត មក ។ តាផាត ឡើងមកម្ដង វ៉ៃគ្នាទៅ ។

វ៉ុះ	វ៉ៃគ្នាទាំងខ្មែរ ៗ ។

ដានីះ	មុនដំបូងមីងទៅក្រែងតាចាយតា៎ មិនមែនតាជាល ទេ?

វ៉ុះ	ចា៎?

ដានីះ	ក្រែងទៅដំបូង?

វ៉ុះ	ទៅដំបូងតាចាយ ។

ដានីះ	តាចាយ ទៅណាទៅ?

រុំៈ តាចាយ មិនដឹងគាត់ទៅណាទៅណីទេឥឡូវ កាលហ្នឹងនៅហ្នឹង ដល់ពេលរត់មកមិនដឹងទៅណាណីទេ កាលរត់មកគាត់មកនៅភ្នំនេះ ភ្នំបារាំងធ្លាក់ ដល់គាត់ចេញពីហ្នឹងទៀត មិនដឹងទៅណាខ្ញុំអត់ដឹងទេ ។ មិនដឹងទៅណានៅណាណី ។

ដានីៈ បន្ទាប់ពីតាចាយ មកអត់ដឹងពីណា?

រុំៈ អត់ដឹងទេ ។

ដានីៈ ចុះតាផាត គាត់ធ្វើអី?

រុំៈ តាផាត គាត់ខាងគណៈឃុំ គណៈស្រុក ។

ដានីៈ គណៈស្រុកណា? សេរីសោភ័ណ្ឌ?

រុំៈ ចា៎!

ដានីៈ ចុះមីងថាតាអីដែលស្លាប់ទៅ? ឈ្មោះតាអី?

រុំៈ តាជឿនមួយទៀតក៏ខ្លាំងដែរ ហ្នឹងខាងគណៈស្រុក ។

ដានីៈ តាណាដែលនៅជិតផ្ទះគាត់?

រុំៈ តាប៉ូ ។

ដានីៈ តាប៉ូ គាត់ធ្វើអី? គណៈតំបន់?

រុំៈ ចា៎ ប៉ុន្តែគាត់ស្លូតណាស់ នៅតាមគាត់រហូត ។

ដានីៈ គណៈតំបន់ណា? គណៈតំបន់៥?

រុំៈ ចា៎!

អ្នកជិតខាងៈ សុទ្ធតែដើងខ្លាំងហើយពួកគាត់ ។

រុំៈ តស៊ូណាស់ មួយហឹកកាលយើងនៅព្រៃ ក្នុងព្រៃនេះហើយ ។

ដានីៈ មីងមកនៅសំរោង មកធ្វើខាងសហករណ៍?

រុំៈ ខ្ញុំនៅសហករណ៍ ធ្វើស្រែ ចំការហ្នឹង ។

ដានីៈ មិនមែនគេឲ្យយើងក្តាប់ប្រជាជនទេ?

អ្នកជិតខាងៈ និយាយធ្វើអី ។

រុំៈ ខ្ជិលវែងឆ្ងាយច្រើនណាស់ ។

អ្នកជិតខាងៈ ធ្វើមេគេណា៎ ។

ដានីៈ ខ្ញុំគ្រាន់តែចង់ដឹងឲ្យវាច្បាស់ ។ កាលហ្នឹងមីងមកនៅសំរោងហ្នឹងយើងគ្នា៥នាក់ហ្នឹង ដឹកនាំគ្រប់គ្រងប្រជាជនធ្វើស្រែ ។

រុំៈ ធ្វើស្រែ ។

ដានីៈ កាលហ្នឹងពីក្រោមមកតាម៉ុក គាត់ធ្លាប់បង្រៀនអី ។

រុំៈ ខ្ញុំមិនមែនអ្នកដឹកនាំទេ គេអ្នកធំជាងខ្ញុំ គ្រាន់តែខ្ញុំចុះរួមជាមួយគេ ជាមួយប្រជាជន ។ មិនមែនខ្ញុំបានទៅដឹកនាំគេ ចុះជាមួយគ្នាហ្នឹងឯង ស្រេចតែគេប្រាប់ គេប្រើឲ្យធ្វើអី ធ្វើហ្នឹងជាមួយគេ ចុះយើងនៅក្មេង ហើយយើងមិនសូវចេះអក្សរផង ។

ដានីៈ កាលហ្នឹងនៅឃុំអី ឃុំសំរោង?

រុំៈ ក្នុងឃុំសំរោង ។

ដានីៈ គណៈឃុំសំរោងពីណាគេ?

រុំៈ គណៈឃុំសំរោង តាជឿន ។

ដានីៈ មីងនៅក្នុងចង្កោមគណៈឃុំនឹងគេដែរ?

រុំៈ ចាំ?

ដានីៈ មីងនៅក្នុងចង្កោមគណៈឃុំគេ?

រុំៈ ខ្ញុំនៅខាងសហករណ៍ ។

ដានីៈ ហើយធ្វើស្រែកាលហ្នឹងធ្វើយ៉ាងម៉េច អីយ៉ាងម៉េចទៅ បានស្រូវច្រើនដែលអត់?

រុំៈ ស្រូវបាត់ដំបងក៏កើតអីកើតម៉្លេះ ខ្ញុំមិនដែលធ្វើទេ ខ្ញុំនៅស្រុកយួនប៉ុន្មាន ៣-៤ឆ្នាំ មិនដូចទៅខាងសំរោងទេ លោកអើយ ស្រូវអើយស្រូវ អីចឹងហូបគ្រប់គ្រាន់ បាយហូបបរិបូរណ៍ មានសាច់ ខ្ញុំមកមានសាច់ មានឈាម ថាខ្ញុំមកមានពេញហ្នឹង ប្រជាជនស្ទើច ហើយមកក្បាលជន្លង់អន្ទុយលិចក្បាល ។

ដានីៈ ក្នុងជួរគណៈស្រុកសេរីសោភ័ណ្ឌហ្នឹង មានពីណានៅរស់ដែលឥឡូវ?

រុំៈ ចាំ?

ដានីៈ ក្នុងជួរគណៈស្រុកនៅសេរីសោភ័ណ្ឌ?

រុំៈ មកពីខាងនោះ?

ដានីៈ បាទ ។

រុំៈ គេនៅរស់ ។

ដានីៈ ពីណាគេ?

រុំៈ តាជឿន នៅគីឡូ១៣នៅរស់ ។

អ្នកជិតខាងៈ អូរ១៣ត្រង់ណានេះ?

ដានី៖ គីឡូ១៣ ។

រ៉ុំ៖ អត់ស្គាល់ផ្សារចូលថៃ គីឡូ១៣ ។

អ្នកជិតខាង៖ ស្គាល់ហើយ ខាងណាគីឡូលេខ៩ ។

រ៉ុំ៖ អត់ដល់ទេ ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអីដែរ?

រ៉ុំ៖ ប្រពន្ធគាត់ឈ្មោះមីងគឿន ។

ដានី៖ គាត់ធ្វើគណៈស្រុកនៅសេរីសោភ័ណ្ឌ?

រ៉ុំ៖ ចា៎!

អ្នកជិតខាង៖ ចុះយាយអីម៉ិញ ចូលភូមិទួល?

ដានី៖ យាយយុទ្ធ ។

អ្នកជិតខាង៖ ស្គាល់យាយយុទ្ធអត់?

រ៉ុំ៖ ស្គាល់ ។

ដានី៖ គាត់ទៅធ្វើសាក្សីនៅតុលាការ គេហៅ គេអញ្ជើញទៅ ។

រ៉ុំ៖ គាត់ទៅ២-៣ដង ខ្ញុំឃើញអីចឹងបានខ្ញុំខ្ជិល ខ្លាចគេហៅទៅ មិនលេងចូលទេខ្ជិល ហ្នឹងហើយ យាយយុទ្ធ ។

ដានី៖ ចុះម៉ិញថាតាជឿន គាត់ធ្វើគណៈស្រុក ។ ក្រែងតាដាត គាត់គណៈតំបន់ ។

រ៉ុំ៖ មានដាន់ថ្នាក់ពូ មានអនុ មានសមាជិក មានប្រធាន ។

ដានី៖ ពីណាគេធ្វើប្រធាន ។

វណ្ណៈ ៖មាន៣រូបអីចឹង?

រ៉ុំ៖ ចា៎ ៣រូប ។

ដានី៖ ពីណាធ្វើប្រធាន?

រ៉ុំ៖ ប្រធានមួយទៀត គ្រាន់តែគាត់មិនបាច់ទៅណា កាលគាត់នៅខាងដងរែក ឥឡូវមិនដឹងឆ្ងាយដល់ណាទេ ។

ដានី៖ ពីណាគេធ្វើប្រធាន ខ្ញុំគ្រាន់តែចង់ដឹងដារចនាសម្ព័ន្ធ?

វណ្ណៈ ៖ឈ្មោះអីទៅ?

រ៉ុំ៖ ឈ្មោះអីភ្លេចហើយ នៅជិតៗនេះចេះតែឃើញមុខគ្នារាល់ថ្ងៃអត់ភ្លេច ។

ដានី៖ គាត់ធំជាងគេបន្ទាប់មកពីណាគេ?

វុំៈ ចាំ?

ដានីៈ បន្ទាប់ពីមីងអត់ប្រាប់ឈ្មោះមិញ ។

វុំៈ បន្ទាប់មកតាប៉ូ, តាផាត បន្ទាប់ជាន់ៗថ្នាក់ ។

វណ្ណៈ ៈតាប៉ូគាត់នៅណាឥឡូវ?

វុំៈ គាត់ស្លាប់បាត់ហើយ ។ ខ្ញុំនៅជាមួយគាត់រហូត ។

ដានីៈ តាប៉ូប្រធាន, អនុ តាផាត ។

អ្នកជិតខាងៈ ថាតាអ៊ីគេចែងភ្លេចឈ្មោះមុិញ?

វុំៈ ចុះពូឯងម៉េចស្គាល់ តាផាត ច្បាស់?

អ្នកជិតខាងៈ ខ្ញុំស្គាល់គាត់តាំងពីនោះ ។

វុំៈ នៅនោះ ។

អ្នកជិតខាងៈ ខ្ញុំកូនចៅគាត់ ។

ដានីៈ ចុះហ្នឹងតាអ៊ីដែលមីងអត់ប្រាប់ហ្នឹងគាត់ធ្វើប្រធាន បន្ទាប់មកតាប៉ូ បន្ទាប់មកតាផាត ហើយពីណាទៀត?

អ្នកជិតខាងៈ ប្រាប់ តាអ៊ីបាត់ខ្លួន ឈ្មោះតាអ៊ី?

វុំៈ តាអ៊ី ។

វណ្ណៈ ៈរកនឹកបន្តិចមកមីង ។

អ្នកជិតខាងៈ តាហ្នឹងរាងទាបៗ ។

វុំៈ ចាំ! រាងទាបៗល្អិត ។

អ្នកជិតខាងៈ តាហ្នឹងស្លាប់អស់នៅសល់តែប្រពន្ធគាត់ ។

ដានីៈ តាណា?

អ្នកជិតខាងៈ តានោះ ។

ដានីៈ ហើយតាជឿន ហ្នឹងគាត់ធ្វើគណៈស្រុកនៅសេរីសោភ័ណ្ឌអីចឹង ។ តាប៉ូ, តាផាត គាត់គណៈតំបន់ ឬគណៈម៉េច?

វុំៈ នៅខាងស្រុកដូចតែគ្នា ។

ដានីៈ ចុះតំបន់ពីណាគេ?

វុំៈ តំបន់ខាងតាញៀន ម៉ង ។

ដានីៈ តាញៀន ប្ដីយាយចែមហ្នឹង ។ ចុះយាយចែម គាត់ធ្វើអី?

រុំៈ	យាយថែម ក៏ធំលើជាង តាញ៉ន ទៀត ។

ដានីៈ	យាយថែម ធំជាងគេទៀត? ធំជាងប៉ុន្មាននាក់នេះទៀត?

រុំៈ	ធំជាងប្តីគាត់ទៀត ។

ដានីៈ	ធំជាងប្តីគាត់ ធំជាងតាប៉ូ, តាផាត ហ្នឹងទៀត?

រុំៈ	យី! ធំ ៗ ផាប់ហើយនារីប៉ុន្មានរាប់ពាន់នាក់លើយាយថែមទាំងអស់ ។

ដានីៈ	ប៉ុន្តែម៉េចបានគាត់អត់នៅស្វាយ គាត់ទៅនៅភ្នំលៀបវិញ?

រុំៈ	គាត់ភៀសៗខ្លួន គេចៗខ្លួន អ្នកធំៗ គេចខ្លួន ។

ដានីៈ	ប៉ុន្តែយាយថែម កាលគាត់មកហ្នឹងមីងស្គាល់គាត់ដែរ?

រុំៈ	ខ្ញុំស្គាល់ អីមិនស្គាល់ ។

ដានីៈ	ស្គាល់ពេលគាត់មកដល់ហើយ ឬពីមុនមកមីងស្គាល់គាត់ដែរ?

រុំៈ	ស្គាល់តាំងពីខ្ញុំនៅកងកុមារ គាត់ខស្សរាហ៍ទៅអប់រំ គាត់ទៅដូចថាទៅធ្វើបុណ្យ ១៧ មករា អីចឹង ដល់ពេលឡើងមានយោបល់ យើងចេះតែសួរគ្នា ប្រាប់ថាឈ្មោះនេះ ឈ្មោះនោះ យើងសួរគ្នាដឹងៗតគ្នា ។

ដានីៈ	គាត់ធ្លាប់ទៅធ្វើបុណ្យ១៧ មេសា នៅខាងគិរីវង្ស?

រុំៈ	នៅខាងថ្មស ។

ដានីៈ	ថ្មស?

រុំៈ	ថ្មស គិរីវង្សហ្នឹង ។

ដានីៈ	ថ្មស គិរីវង្ស?

រុំៈ	នៅព្រំប្រទល់យួន ។

ដានីៈ	កាលហ្នឹងគាត់ធ្វើធំដែរ? កាលនៅ ។

រុំៈ	យី មិនធំ គាត់ធ្វើធំ បើសិនគាត់ធ្វើអាក្រក់គេយកទៅបាត់ហើយ តែគាត់ធ្វើល្អ ។

ដានីៈ	បាទ ធ្វើល្អ ។

រុំៈ	បើថាអាក្រក់គេយកទៅច្រើនណាស់កាលហ្នឹង ។

ដានីៈ	អីចឹងគាត់នៅក្នុងគណៈតំបន់បានគាត់ទៅ?

រុំៈ	គណៈតំបន់ ។

ដានីៈ	គណៈតំបន់ដប់ប៉ុន្មាន?

រុំៈ	តំបន់១៣ ។

ដានី៖ គណៈតំបន់១៣?

រុំ៖ ចា៎!

ដានី៖ ហើយគាត់ទៅអប់រំនារី? គាត់ទៅអប់រំ?

រុំ៖ នារី កុមារឡើងប៉ុន្មានពាន់នាក់ គិតទៅឡើងត្រៀបត្រាទាំងជួរៗ អ៊ូ! គាត់មកមានយោបល់អប់រំ ឡើងចាប់អារម្មណ៍ ។

ដានី៖ គាត់អប់រំពីអីខ្លះទៅ?

រុំ៖ ពីយើងធ្វើការងារ ធ្វើអីៗហ្នឹង ហើយពីរឿងសេដ្ឋកិច្ចយើងហូបអាហារ ដូចអ្នកប្រជាជន ផ្តល់អង្ករ ផ្តល់អីមកឲ្យយើងហូបឆ្អែតៗ ដល់ពេលគេយកទៅនេះធ្វើអីចឹង យកទៅចោល យកទៅទម្លាក់ទឹកអីចឹង ហើយយើងហូបអត់គ្រប់ អត់គ្រាន់ ហើយខំធ្វើស្រូវប្រាំងទៅ បានហូបគ្រប់គ្រាន់ ។

ដានី៖ កាលហ្នឹងមីងស្គាល់តាសោមទេ?

រុំ៖ ចា៎?

ដានី៖ តាសោម ។

រុំ៖ តាសោម ណា?

ដានី៖ តាសោម គណៈតំបន់១៣ ។

រុំ៖ តាសោម ស្គាល់ ។

ដានី៖ តាសោម គាត់ធ្លាប់ទៅអប់រំអីចឹងៗដែរ?

រុំ៖ ទៅអប់រំ ហ្នឹងគាត់ខាងកងទ័ព ។

ដានី៖ ហើយយាយថែម គាត់ខាង?

រុំ៖ ខាងនារី ខាងកុមារ ។

អ្នកជិតខាង៖ ហើយអ៊ំស្គាល់តាមុត, តាម៉េត?

រុំ៖ តាមុត, តាម៉េត ក៏ស្គាល់ ។

អ្នកជិតខាង៖ ប្រពន្ធគាត់ធាត់សាច់សៗ ។

រុំ៖ ហ្នឹងជួនណាទៅប្រជុំនៅស្វាយជួបគ្នា ។

ដានី៖ ដល់ពេលមីងមកស្វាយហ្នឹងតំបន់ប៉ុន្មាន?

រុំ៖ ស្វាយតំបន់ប៉ុន្មានម៉េច?

ដានី៖ នៅស្វាយហ្នឹងគេហៅតំបន់ប៉ុន្មាននៅខាងពាយ័ព្យ?

វ៉ុះ សព្វថ្ងៃគេហៅតំបន់?

អ្នកជិតខាងៈ ទេ លើកមុនតំបន់៥ ។

វ៉ុះ ឥឡូវគេហៅប៉ុន្មាន?

អ្នកជិតខាងៈ ហៅខេត្ត អត់មានតំបន់ទេ ។

ដានីៈ ខេត្តបន្ទាយមានជ័យ ។ កាលហ្នឹងតំបន់៥ អីចឹងមីង?

វ៉ុះ តំបន់៥ ។

ដានីៈ អីចឹងយាយថែម គាត់មកខាងស្វាយហ្នឹងគាត់មកធ្វើជាគណៈតំបន់៥?

វ៉ុះ គណៈតំបន់៥ ។

ដានីៈ គាត់ប្រធានតំបន់៥?

វ៉ុះ ចាំ! នារីពេលហៅនារីប្រជុំម្ដងៗ អីឡើងទៅប្រជុំនៅស្វាយ ។

ដានីៈ គាត់មកប្រជុំនៅស្វាយដែរ ។

វ៉ុះ មក ។

អ្នកជិតខាងៈ គាត់បងឯងតិច ចុះសម្ដេចដែលគាត់សង់ដេកនៅស្វាយកាល៧៩ ដែលរត់មកចែងឯង ដឹងអត់?

វ៉ុះ ចាំ?

អ្នកជិតខាងៈ ដែលសម្ដេចមកពីភ្នំពេញ មកជួបប៉ុល ពត?

វ៉ុះ ដឹងតាំ ។

អ្នកជិតខាងៈ សម្ដេចមកដេកនៅស្វាយហ្នឹង?

វ៉ុះ ចាំ!

អ្នកជិតខាងៈ ម៉េចបានដឹង?

ដានីៈ មីងដឹងដែរកាលហ្នឹង?

វ៉ុះ ដឹងតែខ្ញុំអត់បានទៅមើលទេ ។

ដានីៈ អត់បានឃើញមុខសម្ដេចឪទេ?

វ៉ុះ អត់បានទៅឃើញទេ ។ អត់ហ៊ានបានទៅឃើញទេ ប៉ុន្តែអង្គុយចាំមើលយន្តហោះ ហោះ ឃើញតែយន្តហោះទេ ឃើញតែកង៉ាល់ហោះ កន្ទុំរុយបឹកៗ ។

ដានីៈ យន្តហោះមក?

វ៉ុះ ជិះយន្តហោះមក ។

ដានី៖ ជិះយន្តហោះមកទេ?

វ៉ុំ៖ ចា៎!

ដានី៖ ជិះយន្តហោះមកពីអន្លង់?

វ៉ុំ៖ យើ ឆ្នាំប៉ុន្មានទេកាលហ្នឹង កាលមកឆ្នាំប៉ុន្មាន? ឆ្នាំ៧៩?

អ្នកជិតខាង៖ កាលហ្នឹងស្តេចមក ដែលរត់មកហ្នឹង។

វ៉ុំ៖ ចា៎! រត់មកហ្នឹង។

អ្នកជិតខាង៖ តាផាត ទៅផ្ទាល់ បានជួបផ្ទាល់។

វ៉ុំ៖ តាផាត គាត់ទៅផ្ទាល់ អត់ទេ ពូៗច្រើនទៅផ្ទាល់ យើងនារីៗអត់សូវទេ។

ដានី៖ មីងៗយាយថែម គាត់មកធ្វើគណៈតំបន់៥ ចុះកាលជិនាន់តាចាយ គាត់ធ្វើគណៈតំបន់ដែរ អត់ទេ?

វ៉ុំ៖ ចា៎?

ដានី៖ តាចាយ?

វ៉ុំ៖ តាចាយ ខាងតំបន់ដែរ ប៉ុន្តែគាត់ខាងសេដ្ឋកិច្ច។

ដានី៖ ខាងសេដ្ឋកិច្ច?

វ៉ុំ៖ គាត់នៅខាងសេដ្ឋកិច្ច ដូចម្ហូប ស្បៀង អាហារ អង្ករ។

ដានី៖ ចុះពីណាខាងកងទ័ព គណៈតំបន់ដែរ?

វ៉ុំ៖ ចា៎?

ដានី៖ កាន់ខាងកងទ័ព?

វ៉ុំ៖ កាន់កងទ័ពធំ តាញ៉ែន ហ្នឹងហើយ។

ដានី៖ តាញ៉ែន ឃើញឥឡូវដូចអត់សូវនិយាយស្តី គាត់កាន់កងទ័ពម៉េចគេស្តាប់ទៅ?

វ៉ុំ៖ អ៊ូ! ងាប់។

អ្នកជិតខាង៖ តាញ៉ែន មិនមែនទេ តាញ៉ែន ស្អាតណាស់ និយាយកាលហ្នឹង។

វ៉ុំ៖ និយាយមួយម៉ាត់ និយាយវ៉ោកវ៉ាកអត់ប្រយោជន៍វិញទេ។

អ្នកជិតខាង៖ តាញ៉ែន ស្អាតណាស់។

ដានី៖ គាត់ពូកែនិយាយដែរ?

អ្នកជិតខាង៖ គាត់និយាយគេខ្លាចហើយ តាញ៉ែន ស្អាតណាស់កាលហ្នឹង និយាយសំលុតគេ ដូចហ៊ុន សែនអីចឹង និយាយដូចគ្នា តាញ៉ែន និយាយស្អាតណាស់។

រ៉ុៈ និយាយមួយម៉ាត់ៗ ។

ដានីៈ កាលហ្នឹងឪពុកម្ដាយគាត់នៅស្វាយតាអី? ឪពុកម្ដាយយាយថែម? ក្រុមគ្រួសារបងប្អូនគាត់?

រ៉ុៈ អត់ទេ គាត់នៅតាកែវ គាត់អត់យកមកទេ គាត់មកតែ២នាក់ប្ដីប្រពន្ធ ។

ដានីៈ ចុះប្ដីប្រពន្ធគាត់នៅខុសគ្នា? យាយថែម កាលខ្ញុំជួបគាត់ គាត់ថានៅភ្នំលៀប?

រ៉ុៈ ចុះគាត់ធ្វើការផ្សេង ប្ដីធ្វើផ្សេង ប្រពន្ធធ្វើផ្សេង ។

ដានីៈ ចុះប្ដីគាត់នៅណា តាញ៉ែន?

រ៉ុៈ ចាំ?

ដានីៈ តាញ៉ែន នៅណា?

រ៉ុៈ គាត់ចុះប្រឡូកគ្រប់កន្លែង តាញ៉ែន ។

ដានីៈ គាត់កាន់ខាងកងទ័ព?

រ៉ុៈ ខាងកងទ័ព ។

ដានីៈ ខាងកងទ័ព, ខាងប្រជាជន ហើយខាងនារី ខាងកុមារ យាយថែម?

រ៉ុៈ យាយថែម ។

ដានីៈ អីចឹងប្រជាជនធ្វើស្រែ?

រ៉ុៈ ធ្វើស្រែ ធ្វើអីយាយថែម ។

ដានីៈ ហើយតាចាយ គាត់ខាងសេដ្ឋកិច្ចទេ?

រ៉ុៈ ខាងសេដ្ឋកិច្ច ។

វណ្ណៈ ៈតំបន់ដូចគ្នា ។

អ្នកជិតខាងៈ តំបន់ដូចគ្នា ធំៗដូចគ្នា មានច្រើន វាមានច្រើន ។

ដានីៈ តាចាយ គាត់នៅរស់ទេ?

រ៉ុៈ ចាំ?

ដានីៈ នៅរស់អត់ទេ តាចាយ?

រ៉ុៈ មិនដឹងនៅណា បើបាត់តាំងពីឆ្នាំប៉ុន្មាន ប៉ែតប៉ុន្មានទេ បែកគ្នារហូត ។ កាលឆ្នាំ៨០នៅ គាត់នៅភ្នំកំចាយ នៅជិតភ្នំ ។

ដានីៈ នៅណា?

រុំៈ ហួសភ្នំបារាំងធ្លាក់ ដល់បែកគ្នា កាលខ្ញុំការឆ្នាំ៨១ ចាប់ដៃគ្នានៅបឹងបេង កាលហ្នឹងតាប៉ូ គាត់រៀបឲ្យ គាត់ការឲ្យ ។

ដានីៈ អីចឹងតាប៉ូ, តាផាត, តាជឿន គាត់នៅស្រុកទេ មិនមែននៅតំបន់ទេ?

រុំៈ គាត់នៅតាមស្រុក ចុះតាមសហករណ៍ហ្នឹងម៉ង ចុះផ្ទាល់ គាត់ធ្វើចុះផ្ទាល់ គាត់ធ្វើការផ្ទាល់តែម្តង ធ្វើការផ្ទាល់តែម្តង ។

ដានីៈ គាត់ធ្វើចុះផ្ទាល់ ដូចថាគាត់នៅស្រុកសេរីសោភ័ណ្ឌទេ?

រុំៈ ចា៎!

ដានីៈ កាលហ្នឹងមីងចាំថានៅខាងភ្នំស្រុក ពីណាគេអ្នកទៅគ្រប់គ្រងនៅភ្នំស្រុក?

រុំៈ ភ្នំស្រុក អ្នកកាន់កាប់នៅភ្នំស្រុកច្រើនតែរត់នៅខាងដងរែក ។

ដានីៈ ពីណាគេហ្នឹង?

រុំៈ ពីណាកាលមកជួបជុំគ្នាប្រជុំនៅស្វាយ ពីណាគណៈស្រុក បែកគ្នាភ្លេចអស់ហើយ ។

ដានីៈ ចុះខាងថ្មពួក?

រុំៈ ថ្មពួក, ភ្នំស្រុក ខាងនេះណាណីខ្លះទេ ភ្លេចអស់ ខ្ញុំដឹងតែនៅខាងសំរោងហ្នឹងខ្ញុំចាំ វានៅជិតៗគ្នា ។

ដានីៈ សំរោងពីណាគេ?

រុំៈ ចា៎?

ដានីៈ សំរោង?

រុំៈ សំរោង តាជឿន ។

ដានីៈ តាជឿន ក្រែងគាត់គណៈស្រុកនៅសេរីសោភ័ណ្ឌ?

រុំៈ នៅសេរីសោភ័ណ្ឌ ប៉ុន្តែគាត់ចុះនៅតាមឃុំផ្ទាល់តែម្តង ។

ដានីៈ គាត់សមាជិកស្រុកនៅសេរីសោភ័ណ្ឌ ហើយគាត់កាន់ឃុំសំរោង ។

រុំៈ ចា៎ គាត់ចុះផ្ទាល់តែម្តង ។

អ្នកជិតខាងៈ ចុះតារាម?

រុំៈ តារាម ហ្នឹងខាងនេះវិញទេ ទៅខាងថ្មពួក ថ្មគោល តារាម នៅនេះអូចោទ ។

ដានីៈ ខ្ញុំស្គាល់គាត់ត៎ា ប្រពន្ធគាត់ឈ្មោះ សុខា ។

រុំៈ ហ្នឹងហើយ ។

អ្នកជិតខាងៈ គាត់បន្តិច ចុះអឺស៊ូ ម៉េត បងឯងជួបនៅហ្នឹង ។

រ៉ុះ ចាំ?

ដានីៈ ហើយចុះមីងការងារអី យើងធ្វើការ យើងទៅស្ទូងស្រូវ ធ្វើការងារយ៉ាងម៉េច? ប្រជាជនគាត់ហូបចុកយ៉ាងម៉េច? ហើយធ្វើការងារយ៉ាងម៉េច មីងចាំទេ?

រ៉ុះ ចាំ ។

ដានីៈ ធ្វើម៉េចខ្លះការងារ?

រ៉ុះ ធ្វើម៉េចខ្លះ ហូបបាយតាមសហករណ៍ ហូបបានបរិបូរណ៍ព្រោះស្រុកគេហ្នឹងសំបូរត្រីណាស់ មិនលឺខ្ញុំថាខ្ញុំមកមានសាច់ មានឈាម នៅខាងហ្នឹង ត្រី ដាំបាយទៅ ហូបបានពេញមាត់ ថាស្រូវមហាកើត សឹងកៀរនឹងជើង ស្រូវឪម៉ែស្រូវហើយ ស្រុកគេហ្នឹង ។

ដានីៈ កាលហ្នឹងចុះខាងនៅឃុំសំរោង គណៈឃុំសំរោងពេលប្រជុំមីងចូលរួមជាមួយគេដែរ?

រ៉ុះ មួយអាទិត្យអីគេហៅទៅប្រជុំម្ដង ។

ដានីៈ ប្រជុំហើយគេដាក់ផែនការ ធ្វើការងារម៉េចទៅ?

រ៉ុះ ធ្វើការខាងយើង ដូចថាយើងខាងពីរឿងដោះស្រាយថាយើងពីរឿងហូបចុក កុំឲ្យប្រជាជនថាហូបបបរ ឲ្យហូបបាយឆ្អែតៗគ្រប់គ្រាន់ កាលយើងមកដល់ដំបូងបបរសុទ្ធមែន ខ្ញុំអត់កុហកទេ ហូបបបរម៉ង ខ្ញុំមកហូបបបរនៅសហករណ៍ ។ បានមួយឆ្នាំ បានឆ្នាំក្រោយទៀតបានបាយហូបពេញមាត់ ។

ដានីៈ ចុះយាយចែម គាត់មានដែលមកប្រជុំ មកណែនាំប្រាប់ឲ្យធ្វើការងារ?

រ៉ុះ មកហៅ ដូចថា១០ថ្ងៃ ហៅទៅប្រជុំនៅស្វាយម្ដង បើយើងប្រជុំនៅតាមឃុំសំរោង យើងហៅតាមឃុំហ្នឹងមួយអាទិត្យម្ដងៗ ។

ដានីៈ ដល់១០ថ្ងៃប្រជុំទូទៅ?

រ៉ុះ ហ្នឹងទៅខាងស្វាយ ។

ដានីៈ ទៅទាំងអស់គ្នា?

រ៉ុះ ទៅខាងស្វាយ ។

ដានីៈ ទៅហើយយាយចែម គាត់ធ្វើជាប្រធានអង្គប្រជុំ?

រ៉ុះ ប្រធានអង្គប្រជុំ ។

ដានីៈ ហើយកាលហ្នឹងដូចថាប្រជាជន មុនមីងមកប្រជាជនអត់ស្កូវបានអីហូប លំបាកអីចឹង ដល់ពេលយើងមកគ្រប់គ្រងល្អ...

រ៉ុះ មកបាន១ឆ្នាំ បានបាយហូប

ដានីៈ មួយឆ្នាំដូចថាអ្នកដែលធ្វើឲ្យ ដូចថាធ្វើឲ្យរាំងស្ទះ ប្រជាជនហូបមិនបាន ហូបមិនឆ្អែតអី យើង ចាប់យកទៅទុកនៅណាទៅ?

រ៉ុៈ អត់ដឹង ។ គេហៅយកទៅមិនដឹងយកទៅណា ។ អត់ដឹងដែរ ខ្ញុំអត់ដឹងដែរ ។

ដានីៈ យើងអ្នកហៅឲ្យគេទៅ?

រ៉ុៈ អត់ទេ ឃើញគេមកហៅតែម្តង មិនដឹងគេនេះម៉េច ។

ដានីៈ ពីណាមកហៅ?

រ៉ុៈ ខាងខេត្តគេមកហៅតែម្តង ហៅយកទៅ មិនដឹងគេហៅយកទៅណាខ្ញុំអត់ដឹងដែរ ។

ដានីៈ ខាងខេត្តខាងណា?

រ៉ុៈ ចា៎?

ដានីៈ កាលហ្នឹងអត់មានខេត្តណា ក្រែងតំបន់?

រ៉ុៈ ទេ គេថាកងទ័ពពីខេត្តៗមក មិនដឹងខាងណាៗ សុទ្ធតែដាក់ឡាន ។

ដានីៈ ខេត្តខាងណា? បាត់ដំបង ឬពីស្វាយ?

រ៉ុៈ មិនដឹងខេត្តពីណាមក គេហៅពួកកងខេត្តៗមក ឃើញគេហៅទៅ មិនដឹងគេហៅទៅប្រជុំ ឬគេហៅទៅណា បើអត់ដឹងដែរ ចេះតែបាត់ទៅ ។

ដានីៈ អ្នកដែលធ្វើឲ្យប្រជាជនហូបអត់ឆ្អែត ធ្វើឲ្យប្រជាជនស្លាប់អីហ្នឹង កងទ័ពគេមកហៅយកទៅ?

រ៉ុៈ ចា៎!

ដានីៈ ចុះនៅតំបន់៥ហ្នឹងមានកន្លែងគុក កន្លែងសន្តិសុខគេដែលអត់?

រ៉ុៈ កន្លែងគុក កន្លែងសន្តិសុខនៅស្វាយហ្នឹង ។

ដានីៈ នៅស្វាយហ្នឹង?

រ៉ុៈ ចា៎!

ដានីៈ នៅស្វាយនៅម្តុំណា? មីងស្គាល់អត់?

រ៉ុៈ និយាយម្តុំអីចឹងមិនដឹងកន្លែងណា អត់ស្គាល់កន្លែងសន្តិសុខនែក កាលឆ្នាំ៧៧-៧៨ ពួងនៅហ្នឹងអត់ដឹង ។

អ្នកជិតខាងៈ គេសម្លាប់តែចំការខ្នុរតូច បើតាផាត គាត់ដឹងទាំងអស់ ។

រ៉ុៈ បើតាផាត គាត់នៅកៀកហ្នឹង ផ្ទាល់ដឹង គាត់អ្នកធំ ដូចយើងដឹងតែព្រលឹមឡើងចុះធ្វើការជាមួយប្រជាជន ហើយបើគេអ្នកធំៗ ដូចតាផាត ដូចតា អីចឹងគាត់មានដែលចុះទៅ ស្រែណា៎

តែយើងតាំ យើងម៉េចដឹង ។ គេខាងធ្វើការក្នុងភូមិ ចុះឡើងៗយកអ្នកណាៗ គេខាងហ្នឹង យើងកាលហ្នឹងមានដឹងអី ស្រេចគេប្រើ គេប្រាប់ហ្នឹង ។

ដានី: តែខ្ញុំអត់បានជួបតាផាត គាត់ស្លាប់បាត់ហើយ ។

រ៉ុំ: ទើបនឹងស្លាប់ ។

ដានី: ហើយមានពីណាដែលអាចជួបគាត់បាន ដែលគាត់ដឹងរឿងច្រើន ក្រៅពីតាផាត ។

រ៉ុំ: ចុះមិនសួរប្រពន្ធគាត់ ។

ដានី: ប្រពន្ធគាត់ក្រោយនេះគាត់នៅក្មេងដូចមីងដែរ ។

រ៉ុំ: ហ្នឹងហើយនីរសាផ្ទាល់ប្រពន្ធហ្នឹងម៉ង ។

អ្នកជិតខាង: គាត់មិននិយាយៗ បើអ៊ំអត់ហ៊ាននិយាយ បើថែហ៊ាននិយាយ បើអ៊ំអត់ហ៊ាននិយាយ គាត់ខ្លាច បើថែហ៊ាននិយាយចេញ អ៊ំផាតនិយាយទាំងអស់ ។

រ៉ុំ: គាត់នីរសាផ្ទាល់តែម្តង ។

ដានី: ចុះប្រពន្ធតាផាត?

រ៉ុំ: ប្រពន្ធគាត់ស្លាប់ទៅ បងផល គាត់ស្លាប់ទៅ ។

ដានី: បងផល ហ្នឹងធ្វើអីកាលជំនាន់ហ្នឹង?

រ៉ុំ: បងផល មេឃុំ ។

ដានី: ឃុំណា?

រ៉ុំ: ឃុំទឹកថ្លា ។

ដានី: ផ្ទះតាផាតគាត់នៅម្កាក់?

រ៉ុំ: ចាំ!

ដានី: ម្កាក់ហ្នឹងកន្លែងអី កន្លែងស្រុក?

រ៉ុំ: ឃុំម្កាក់ហ្នឹង ។

ដានី: ខ្ញុំអត់ដឹង ដល់ពេលអត់ដឹងចេះតែច្របូកច្របល់ ។

រ៉ុំ: ដល់នេះប្រពន្ធគាត់នៅសព្វថ្ងៃហ្នឹង នីរសារប្រពន្ធគាត់ផ្ទាល់តែម្តង ដល់ស្លាប់ប្រពន្ធដើម គាត់យកនីរសាហ្នឹងធ្វើប្រពន្ធម្តង ដល់សួរប្រពន្ធគាត់ដឹងៗហើយ គាត់នៅផ្ទាល់ហើយ ។ បើគាត់មិនហ៊ាននិយាយធ្វើម៉េច ។

អ្នកជិតខាង: គាត់មិនហ៊ាននិយាយ បើអ៊ំផាត ហ៊ាននិយាយ ។

វុំៈ បើអឺដាត គាត់និយាយ គេមកសម្ភាសន៍គាត់កាលគាត់មិនទាន់ស្លាប់ពីខែមុនហ្នឹង គេមកសម្ភាសន៍ផ្ទាល់ គាត់និយាយទាំងអស់ ។

ដានីៈ ពីណាមកសម្ភាសន៍?

វុំៈ ខាងអង្គការ ។

ដានីៈ មានគេសម្ភាសន៍ច្រើនមុនហ្នឹង ។

វុំៈ មុនហ្នឹង តាដាត ចាំមើលហៅខ្ញុំ ហៅចាស់ៗពីអាយុហាឡើង ហៅប្រជុំនឹងវត្ត ហៅគាត់សួរម្ដងម្នាក់ៗ គាត់ឲ្យវង្វេរន់សារុង, ក្រមា ។

អ្នកជិតខាងៈ បងលក្ខិណាអ្នកឲ្យមក ។

ដានីៈ ក្រៅពីបងលក្ខិណា មានពីណា?

អ្នកជិតខាងៈ អត់មានទេ ។

ដានីៈ ហើយមីងមកនៅស្វាយហ្នឹងសប្បាយទេ?

វុំៈ ចាំ?

ដានីៈ សប្បាយទេមកនៅស្វាយ?

វុំៈ មានអីឲ្យតែបានហូបគ្រប់គ្រាន់ នារីណាក៏ដូចនារីណាដែរ គ្នាមានសាច់ មានឈាម ឲ្យតែបានស៊ីឆ្អែតគ្នាអរចង់ងាប់ ។

ដានីៈ ដូចថាមកនៅហ្នឹងសប្បាយទៅ មានអារម្មណ៍ភ្លេចផ្ទះដែលអត់?

វុំៈ ដល់អីចឹងភ្លេចផ្ទះ ដល់ពេលគេជ្រើសរើសកងសិល្បៈទៀតទៅ យប់ឡើងរាំឲ្យប្រជាជនមើលទៅរិតសប្បាយភ្លេចផ្ទះ លែងនឹក លែងនាតែម្ដង ដល់កន្លែងហ្នឹងលែងនឹក លែងនា កាលនៅនោះតែល្ងាចស្មានហ្នឹងអង្គុយសំកុក ។

ដានីៈ នៅណា?

វុំៈ នៅជិតស្រុកឃ្មួន នៅទន្លេបាសាក់ ងាកទៅលិចមើលឃើញទឹករលកភឹបៗមកគិតតែ អង្គុយយំនឹកស្រុក ដល់ពេលបានមកនៅមានសាច់ មានឈាមនេះភ្លេច ថាភ្លេចតែម្ដង ខ្ញុំថាភ្លេចៗម៉ង សប្បាយមានសាច់ មានឈាមហ្នឹង ទល់សព្វថ្ងៃអត់ទាន់ស្គាល់ទៅស្រុក ម៉េចដង អត់ហ៊ានចូល មិនដឹងស្រុកបែរមុខទៅណា ម៉ែស្លាប់ទៀតក៏លែងហ៊ានទៅ ។

ដានីៈ ទៅលេងស្រុកបានប៉ុន្មានដងហើយ តាំងពីផ្ដាច់ខ្លួនមក?

វុំៈ តាំងពីផ្ដាច់ខ្លួនមកប្អូនមកហៅនាំទៅលេងម្ដងគត់ ។

ដានីៈ ប្អូនមកនាំទៀត អត់ទៅខ្លួនឯងទេ?

រុំ៖ ទៅលេងម៉េចបើមិនស្គាល់ផង ថ្នាក់ប្អូនមក អានេះពីណាគេ គេសួរដឹងថាខ្ញុំនៅហ្នឹងហើយ ខ្ញុំថាខ្ញុំគ្មានប្អូនទេ អត់មានប្អូនទេ ប្អូនខ្ញុំខ្ញុំចេញមកនៅតូចៗសោះ ខ្ញុំអត់មានប្អូន អត់មានអី វាបែរចេញទៅ វាស្រក់ទឹកភ្នែកលើកដៃជូត ខ្ញុំផាកឃើញប្អូនខ្ញុំមែនទេដឹង វាឆ្អែតចិត្តថាមករកបងហើយ ដល់ពេលបងថាអត់មានប្អូន វាស្រក់ទឹកភ្នែក ខ្ញុំនឹកអាណិតផាកមើលវាទៅ វាស្រក់ទឹកភ្នែកលើកដៃជូតទឹកភ្នែក ដល់នេះផែងឈ្មោះអីចឹង? បានរៀបរាប់ទៅហក់អោបប្អូនថាយំទាំងបង ទាំងប្អូន ។

ដានី៖ គាត់មករកមីង?

រុំ៖ អាក្រក់ដល់ថ្នាក់មករក អីចឹងបានថា ហើយវានៅអីតាកែវ វាសុខចិត្តមករកតាំងពីប៉ៃលិនដេកប៉ៃលិន២យប់ មកតាមរក ជិះម៉ូតូឌុបគេមក តាមដល់ខ្លែម ដល់ត្រង់ហ្នឹង មកសួររកដល់ផ្ទះ ចូលផ្ទះម៉ែអាដេង តាផាត ។ អ៊ំផាតប្រាប់មកចំហើយ នៅតែខ្ញុំអត់មានប្អូនទៀតទេ នឹកស្មានវាងាប់អស់ហើយ ។

ដានី៖ អីចឹង ម៉េចបានមីងស្មានថាអីចឹង?

រុំ៖ ទេ ដូចថាគ្មាននៅរស់ទេ កាលសម័យហ្នឹងមិនដឹងរត់ទៅណាណី ខ្ញុំគ្មានសង្ឃឹមថាប្អូននៅរស់ទេ ។

ដានី៖ មីងស្រម៉ៃថាគាត់ស្លាប់អស់ដោយសារយួនចូលមក យួនសម្លាប់ ។

រុំ៖ យួនសម្លាប់អស់ ។

ដានី៖ មីងគិតថាយួនចូលមកសម្លាប់អស់តែម្តង ។

រុំ៖ ហ្នឹងហើយ ខ្ញុំអត់មាននឹកថានៅរស់ទេ ។

ដានី៖ កាល់ហ្នឹងមីងគិតដោយខ្លួនឯង ឬកាលហ្នឹងមាន?

រុំ៖ គិតដោយខ្លួនឯង ។

ដានី៖ ម៉េចបានមីងគិតថាឲ្យតែយួនចូលមក សម្លាប់ខ្មែរអីចឹង?

រុំ៖ កាលហ្នឹងវានៅកៀកនឹងយួន វានៅកៀកយួនពេក គ្មានគិតថាវានៅរស់ទេ ។

ដានី៖ និយាយអារម្មណ៍យើងដោយសារឃើញយួនចូលមក អីចឹងគិតថាយួនស្អប់ខ្មែរ ឬខ្មែរស្អប់យួនអីម៉េច?

រុំ៖ យួនស្អប់ខ្មែរ កាលហ្នឹងកាត់ក្បាលខ្មែរដាំទឹកតែអុងហើយ អាណាមិនថានៅរស់ ខ្ញុំថាអត់នៅរស់ទេ ។

ដានី៖ ពីណាប្រាប់មីងថាយួនកាត់ក្បាលខ្មែរដាំតែអុង?

រុំ៖ ចាំ?

ដានីៈ ពីណាអ្នកប្រាប់?

រ៉ុៈ មិនបាច់ពីណាប្រាប់បើឃើញនៅព្រំដែនហ្នឹងហើយ ។

ដានីៈ ឃើញម៉េច?

រ៉ុៈ ឃើញយួនកាត់ក្បាលខ្មែរ មកដល់ឃើញ ។

ដានីៈ មីងឃើញផ្ទាល់ភ្នែកតែម្ដង?

រ៉ុៈ យួនដេញព្រួទៅ គ្នាអ្នករត់អត់រួច ប្រជាជនគ្នាកូនរញ៉េរញ៉ៃ រត់អត់រួច យើងអ្នករត់រួច ចូលដីថៃ សុំថៃចូល សុំទាហានចូល យើងកងទ័ពវៃមកវិញ មិនចូលមកវិញ ឃើញកាត់ក្បាលដាំទឹកតែ ឲ្យខ្ញុំថាម៉េច ។

ដានីៈ នៅណា?

រ៉ុៈ នៅព្រំយើងហ្នឹង ។

ដានីៈ មីងនិយាយម៉ិញនៅព្រំដែនថៃ ។

រ៉ុៈ ដីយើងមិនព្រំដែនថៃ ថាព្រំដែនអី?

ដានីៈ ម៉េចថាយួនកាត់ក្បាលនៅព្រំដែនថៃវិញ?

រ៉ុៈ ដីយើង ចុះយើងមិននៅជាប់ព្រំដែនថៃ?

ដានីៈ បាទ ។

អ្នកជិតខាងៈ ព្រំនៅជិតបង្កើយ ។

រ៉ុៈ ហ្នឹងហើយ ។

ដានីៈ តែខ្ញុំឆ្ងល់ថា ។

រ៉ុៈ នៅនឹងដីយើងហ្នឹង ។

ដានីៈ តែយួនអ្នកកាត់ក្បាលយើង?

រ៉ុៈ យួនកាត់ក្បាលខ្មែរដាំទឹកតែអុង ។

ដានីៈ អ្ហ៎! សម័យឆ្នាំប៉ែតជាងដែលយួនចូលមកដល់ហ្នឹង ។

រ៉ុៈ ចា៎! ឆ្នាំ៨០ ។

ដានីៈ ដែលយួនវៃយើងចូលដីថៃទៅ ដល់ពេលយួនចូលមកចាប់បាន ។

រ៉ុៈ ដែលគ្នារត់មិនរួចចាប់បាន កាត់ក ។

ដានីៈ កាត់កហើយដាំតែទៀត?

រ៉ុៈ ដាំទឹកតែអុង ឲ្យមេវាទៅ ។

ដានី៖ មីងបានឃើញផ្ទាល់ភ្នែក ឬលឺគេនិយាយ?

រ៉ុំ៖ ទេ! មកឃើញតែក្បាល ។

ដានី៖ មកឃើញតែក្បាល?

រ៉ុំ៖ ក្បាលខ្មោចទឹកតែអុងនៅហ្នឹង ថាយួនកាត់ក្បាលដាំទឹកតែអុង ។

ដានី៖ ព្រោះខ្ញុំសួរហ្នឹង ចង់ដឹងឲ្យឃើញការពិត ។

រ៉ុំ៖ ម៉េចឃើញយួន បើមិនហ៊ានឲ្យយួនឃើញតិចផង រត់ ។

ដានី៖ តែយើងអត់ឃើញផ្ទាល់ភ្នែកថាយួនដាំតែ?

រ៉ុំ៖ ចា៎!

ដានី៖ ឬខាងពូៗគាត់មកគាត់និយាយប្រាប់មីង?

រ៉ុំ៖ អត់ទេ កាលហ្នឹងខ្ញុំនារីនៅលីដែកប្រហោងនៅឡើយទេ ពេញតែម្ដង ។

ដានី៖ ខ្ញុំសុំបកទៅក្រោយបន្តិច កាលមីងនិយាយថាមីងនៅទន្លេបាសាក់ កន្លែងហ្នឹងអត់សូវបានហូបចុកគ្រប់គ្រាន់ យើងលំបាកយើងនឹកផ្ទះ ដល់ពេលមីងមកសំរោង មកនៅឃុំសំរោង នៅសេរីសោភ័ណ្ឌសប្បាយ លែងសូវនឹកផ្ទះហើយ?

រ៉ុំ៖ នៅបាន២ឆ្នាំអត់នឹកផ្ទះ ដូចសប្បាយស៊ីគ្រប់គ្រាន់ទៅ ។

ដានី៖ ពីខែ៦ ឆ្នាំ៧៧រហូតដល់៧៩នៅហ្នឹង?

រ៉ុំ៖ ចា៎!

ដានី៖ នៅបានយូរដែរ?

រ៉ុំ៖ នៅបានយូរ នៅទល់នឹងរត់ រត់មកហ្នឹងតែម្ដង អត់មានបានទៅណាទៀត ។

ដានី៖ ហើយកាលហ្នឹងដូចថាពេលដែលយើងប្រជុំ ពេលរៀបចំផែនការ យើងបានជោគជ័យអត់?

រ៉ុំ៖ ចា៎?

ដានី៖ ជោគជ័យដូចថាអនុវត្តន៍តាមផែនការ កាលពីប្រជុំមកពីតាកែវមក តាម៉ុក គាត់ប្រជុំប្រាប់កាលហ្នឹងមីងនៅក្មេងៗ ហើយ៤០០-៥០០នាក់ ថាយើងមកនេះ យើងប្រយ័ត្នប្រយែងយើងប្រឹងធ្វើការងារ ហើយខាងនេះដូចថាមានពួកក្បត់ច្រើន យើងប្រយ័ត្នអីចឹង ដល់ពេលគាត់និយាយពីហ្នឹងមក មកដល់នេះឃើញជាក់ស្ដែងដូចគាត់ និយាយដែលអត់?

រ៉ុំ៖ ដូចគាត់និយាយ ។

ដានី៖ ដូចគាត់និយាយដែរ?

រ៉ុំ៖ ដូចគាត់និយាយ ។

ដានី៖ ពួកក្បត់ធ្វើអីខ្លះទៅ?

វ៉ុំ៖ ពួកក្បត់យើងវាតាមចាប់យើង ដល់យើងរត់គៀន ពួន តែមកនេះហើយអត់មាននៅ តាមផ្ទះបានទេ ខ្ញុំចូលក្នុងស្រូវវាដើររកដូចស្អី ។

ដានី៖ ពួកក្បត់ហ្នឹងពួក?

វ៉ុំ៖ មិនដឹងពួកណា លឺសូរតែមាត់ ។

ដានី៖ ពួកធ្វើការនៅកន្លែងភូមិ-ឃុំ សហករណ៍ពីមុនយើងមកឬក៏ពួកក្បត់មកពីណា?

វ៉ុំ៖ មិនដឹង មិនដឹងពួកខាងណា ខ្ញុំមក គិតទៅពួកនារីៗគ្នាមួយផ្ទះគ្នា៧-៨នាក់ តែមកឃើញទ្រនាប់ជើងយប់ឡើងវាមកហើយ អាខ្លះហក់តាមបង្អួច រត់ទៅចូលក្នុងស្ទឹងទៅ ខ្លះមានជង្រុកចូលក្រោមជង្រុក ។ ខ្ញុំបានប្រជាជននៅសំរោង កូនអើយកូនឯងចូលក្រោមជង្រុកស្រូវនេះទៅគេមករកកូនឯងហើយ ចូលសំងំនៅហ្នឹង គេជួយលាក់ទៀត ស្អែកឡើង យប់ឡើងមិនទាន់ចុះពីលើផ្ទះទាន់ផង វារត់ឡើងផ្ទះ បើកទ្វារទៅខ្ញុំនៅលើមេដំបូល ។

ដានី៖ មីងកាលនៅតាកែវដូច តាម៉ុក គាត់ធ្លាប់ប្រាប់អីចឹង ពេលយើងមកដល់ស្វាយហើយយាយចែម គាត់ប្រជុំគាត់មាននិយាយប្រាប់ថា យើងត្រូវប្រយ័ត្នប្រយែង កុំឲ្យពួកក្បត់ចាប់យើងអី គាត់ប្រាប់អីចឹងដែរ?

វ៉ុំ៖ ប្រាប់ ។

ដានី៖ ពេលដែលប្រជុំម្តងៗគាត់ប្រាប់អីចឹងរហូត ឬក៏?

វ៉ុំ៖ ប្រជុំម្តងៗប្រាប់អីចឹងរហូត ឲ្យខំប្រឹងធ្វើការ កុំទៅដាច់ដោយឡែកតែ១-២នាក់ អីកុំឲ្យមានគ្នាដូចថា៥-៦នាក់ ទៅទាំង៥-៦នាក់ទៅ កុំឲ្យដាច់១-២នាក់ បាត់ខ្លួនច្រើន ។

ដានី៖ ១០ថ្ងៃគាត់ប្រជុំម្តង? ១០ថ្ងៃយាយចែមប្រជុំម្តង?

វ៉ុំ៖ ចា៎!

ដានី៖ ទាំងអស់ប្រមូលមកប្រជុំ?

វ៉ុំ៖ ទាំងអស់ ប្រមូលមកហៅ ។

ដានី៖ ប្រមូលតាំងពីថ្មពួក?

វ៉ុំ៖ ចុះនីវសារ មិនមែនមានតាមទូរស័ព្ទដូចឥឡូវណា ។

ដានី៖ តាំងពីថ្មពួក, ស្វាយចេក, សេរីសោភ័ណ្ឌ, ព្រះនេត្រព្រះ មកប្រជុំគ្នា?

វ៉ុំ៖ ប្រជុំនៅស្វាយ ។

ដានី៖ ១០ថ្ងៃមកប្រជុំម្តង?

រុំៈ ចាំ!

ដានីៈ ពេលហ្នឹងមកប្រជុំប្រាប់ យើងមានអារម្មណ៍ថាយើងធ្វើការជាមួយអ្នកស្រុកហ្នឹង អ្នកធ្លាប់ធ្វើការពីមុនមក ឃើញដូចខ្លាច ឬឃើញស្អប់ យើងមានអារម្មណ៍ហ្នឹងដែរ?

រុំៈ អត់ទេ គាត់ចូលចិត្ត រាប់អានគាត់ដូចជាម៉ែឪ ។

ដានីៈ ប៉ុន្តែដូចកាលប្រជុំខ្លាចពួកក្បត់ កុំឲ្យយើងដើរ?

រុំៈ ខ្លាចពួកក្បត់ ប្រជាជនតាមមើលទៅដូចអត់មាន ម៉ែៗ ពុកៗ នៅភូមិដូចអត់មានធ្វើបាប ស្អប់យើងទេ មិនដឹងពីណាមក ឆ្ងល់ឲ្យតែយប់ឡើងយើងដូចជាយ៉ាប់តែម្តង ។

ដានីៈ យើងមានអារម្មណ៍ខ្លាចពេលណានេះ?

រុំៈ បើសិនជាយើង ប្រជាជនក្នុងភូមិហ្នឹងស្អប់យើងរត់ចេញខាកទៅ រត់តាមក្រោមផ្ទះ ប្រជាជន ប្រជាជនហ្នឹងប្រាប់ចាប់យើងបាត់ហើយ នេះប្រជាជនជួយលាក់យើងវិញ ឆ្ងល់អីចឹង ឆ្ងល់ដែរ ។

ដានីៈ ប៉ុន្តែពេលដែលយើងទៅណារាងដាច់តែម្នាក់ឯង យើងមានអារម្មណ៍ថាខ្លាចទេ?

រុំៈ ខ្លាចដែរ គេចាប់បាត់តែម្តង បាត់គ្នាច្រើន ។

ដានីៈ មានបាត់គ្នា?

រុំៈ បាត់ ។

ដានីៈ បាត់ប៉ុន្មាននាក់ទៅ?

រុំៈ បាត់មិនចេះតិចទេ បំផុតរឿងពួកអ្នកមកក្រោយ នារីៗមកសារក្រោយជាមួយប្រជាជន ជាមួយតាផាត មួយវគ្គក្រោយ ច្រើនពួកអ្នកស្រែអំបិល មកក្រោយ ។

ដានីៈ មីងបើមីងជួបយាយថែម មីងស្គាល់គាត់ទេ? យាយថែមស្គាល់មីងទេ?

រុំៈ ទៅរកមិនគិតឆ្នាំទេ តាំងពីនៅជំទង់ ហើយឥឡូវយើងចំណាស់នេះមានកូន ទាំងចៅទៀត ហើយ ដូចភ្លេចហើយ ម៉ែខ្ញុំនៅភ្លេចផង ។

ដានីៈ ប៉ុន្តែបើមីងឃើញមុខយាយថែម?

រុំៈ ឃើញប្រហាក់ប្រហែលស្គាល់ ។

ដានីៈ ប៉ុន្តែយាយថែម អាចមិនស្គាល់មីងទេមើលទៅ ។

រុំៈ អាចមិនស្គាល់ព្រោះកាលហ្នឹងយើងចាស់ហើយ កាលហ្នឹងយើងយជំទង់ យើងនៅពេញជំទង់ ។

ដានីៈ តែបើមីងនិយាយពីការងារ ប្រាប់ប្រវត្តិ?

រ៉ុៈ ប្រាប់ប្រវត្តិគាត់ដឹង ។

ដានីៈ តាញ៉ែន ស្គាល់មីងទេ?

រ៉ុៈ តាញ៉ែន គាត់ស្គាល់យើងមិនអស់ទេ ។ គាត់មកប្រាប់ប្រធានកង ប្រធានក្រុមអីចឹងទៅ ៣-៤-១០មាត់គាត់ទៅបាត់ហើយ មិនមែននៅផ្តាំផ្ញើរអីនិយាយច្រើនទេ ។

ដានីៈ គាត់អត់ចេះនិយាយច្រើន?

រ៉ុៈ តាហ្នឹងអត់ចេះនិយាយច្រើន មួយម៉ាត់ដឹងមួយម៉ាត់ហើយ ។

ដានីៈ បើគាត់មកមានការ មកនិយាយប្រាប់យើងចប់ទៅវិញបាត់ហើយ?

រ៉ុៈ មកប្រាប់តែមេកង មេក្រុមហ្នឹង ហ្នឹងគាត់ទៅបាត់ហើយ គាត់មិនចេះនៅរញ៉េរញ៉ៃអីច្រើន ហើយយើងមិនមែនមេ គ្រាន់តែសមាជិកធម្មតាគាត់មានទៅស្គាល់យើងណា ។

ដានីៈ តាម៉ុក គាត់មានដែលមកលេង មកណែនាំយើងនៅស្វាយដែរអត់?

រ៉ុៈ តាម៉ុក កម្រណាស់ មួយខែអី កាលហ្នឹងមកខែប៉ុន្មានមកម្តងដែល ខ្ញុំនៅស្វាយមកប្រជុំ កាលហ្នឹងមកប្រាប់ដំណឹងថា យកប្រជាជនមកតាមក្រោយគ្នា ១០០០គ្រួសារ ហើយនារីមក ៥០០នាក់ដែល ប៉ុន្តែយកមកពួកគេខាងស្រែអំបិល ។

ដានីៈ ឆ្នាំណា?

រ៉ុៈ កាលហ្នឹងឆ្នាំ៧៧ ប៉ុន្តែដើមឆ្នាំ ។

ដានីៈ មីងមកឆ្នាំ៧៧ មីងមកខែ៦ ចុះគាត់មកប្រាប់ហ្នឹងខែប៉ុន្មាន?

រ៉ុៈ ចា៎?

ដានីៈ មីងមក?

រ៉ុៈ ខ្ញុំមកបាន៣ខែគាត់មកប្រាប់ ។ មិនដឹងខែប៉ុន្មានៗ ។

ដានីៈ ខែ៩ ។ ចុះមីងមកខែ៦អីចឹង?

រ៉ុៈ ចា៎!

ដានីៈ មីងមកបាន៣ខែ បានតាម៉ុក គាត់មកប្រាប់ថានារី៥០០នាក់មក ហើយប្រជាជន នារីមកពីស្រែអំបិល?

រ៉ុៈ មកស្រែអំបិល មកក្រោយហ្នឹងចុះធ្វើការ ប្រជាជនកាប់សាប់ដូចស្អីអីចឹង ។ វាទឹកត្រឹមៗនេះ ហើយចុះស្ទូង ជួនណាដាច់ឡែក១-២នាក់ មិនសូវចេះដើរចូលជាមួយពួកកងនារីយើងទេ គេវាងផ្សេង យើងផ្សេង យើងខាងតំបន់ គេខាងស្រែអំបិល ។

ដានីៈ ប៉ុន្តែមីងមក៣ខែ ហើយក្រុមប្រជាជនមក១០០០នាក់ មកក្រោយមីងប៉ុន្មានខែ?

វុំៈ មកក្រោយ ។

ដានីៈ ក្រោយមីងវយៈពេលប៉ុន្មាន?

វុំៈ ៣ខែប្រជាជនហ្នឹងមកតាមក្រោយ ។

ដានីៈ នារីស្រែអំបិលមកក្រោយប្រជាជនហ្នឹងទៀត?

វុំៈ មកជាមួយប្រជាជន មកជាមួយគ្នា ជិះឡានមកជាមួយគ្នា ជិះរទេះភ្លើង ។

ដានីៈ ប្រហែលខែ៨-៩?

វុំៈ មិនដឹងខែប៉ុន្មានទេ ។

ដានីៈ ភ្លៀងខ្លាំងនៅកាលហ្នឹង ហើយស្ទូងស្រូវអីបាន?

វុំៈ ស្បៀយហើយ ស្រូវកំពុងគល់ខ្លះ ប្រជាជនច្រូតបានកិនខ្លះហើយកាលហ្នឹងមិនដឹង មកកាលហ្នឹង

ដានីៈ ដឹងតែក្រោយមីង៣ខែ?

វុំៈ មកក្រោយ សួរប្រពន្ធតាផាត មកក្រោយខ្ញុំ ។

ដានីៈ ចុះមីងកាលហ្នឹងមីងមិនទាន់មានគ្រួសារណា?

វុំៈ នៅ នៅជិទង់ ។

ដានីៈ អាយុប្រហែលប៉ុន្មានឆ្នាំ?

វុំៈ មិនលឺខ្ញុំថា ខ្ញុំមកពេញក្រមុំនៅ ។

ដានីៈ ពេញក្រមុំអាយុប្រហែលជប់ប៉ុន្មានទៅ?

វុំៈ ១៥-១៦ហ្នឹង មិនដឹងជប់ប៉ុន្មាន ។

អ្នកជិតខាងៈ អត់ដឹងខ្លួនឯងពេញជប់ប៉ុន្មានផង ។

ដានីៈ អីចឹងមកពីតាកែវ ។

វុំៈ អត់ទេ យើងហូបមានសាច់ មានឈាម យើងឆាប់នេះមានបណ្តោយ ត្រូវពេញ សាច់ស្អាតណាស់ ប្រជាជនមកសរសើរ អន្ទុយសរសើរ ប្រជាជនចូលចិត្តណាស់ ហើយថ្ងៃល្ងាចជិតយប់ហ្នឹងអត់មានសភាពអីហ្នឹង ពូផាតមកហើយកាន់កាប់ ចាប់កាលពួកតានេះទៅអស់ ។

ដានីៈ ចាប់តាណា?

អ្នកជិតខាងៈ តាវ៉ាល់?

វុំៈ ហ្នឹងហើយ ។

ដានីៈ មីងមកទាន់តាហឹង អត់?

វុំៈ ទាន់ៗ ម៉េចពូឯងបានស្គាល់តាហឹង ហ្នឹង?

ដានី៖ ខ្ញុំអាន អ្នកខាងស្រាវជ្រាវកាលហ្នឹងខ្ញុំស្គាល់ ។

អ្នកជិតខាង៖ គាត់មកសម្ភាសន៍គាត់មិនស្គាល់ ស្គាល់ទាំងអស់ហ្នឹងឯង ។

ដានី៖ អីចឹងទាន់តាហឹងដែរ? ចុះតាជាល ក៏ទាន់ដែរ?

វុំ៖ តាជាល ក៏ស្គាល់ ទាន់ដែរ ខ្ញុំមកតាជាល អត់ទាន់គេយកទៅណាទេ ។

ដានី៖ តាហឹង គេយកទៅនៅ?

វុំ៖ តាហឹង ក៏អត់ទាន់យកទៅដែរ ប៉ុន្តែ តាហឹង យកទៅមុនតាជាល ។

ដានី៖ យកទៅមុនតាជាល?

អ្នកជិតខាង៖ ចុះតា ត្រក?

វុំ៖ តាណាៗទេ ក្រោយ៣នាក់ហ្នឹងយកទៅក្រោយទេ ។

ដានី៖ ចុះតាហឹង, តាជាល ពីណាទៀត?

វុំ៖ តាអី? កាលហ្នឹងបាត់៣នាក់ ។

អ្នកជិតខាង៖ តាវ៉ល់?

ដានី៖ អៀង ឡៃ, តាឡៃ?

វុំ៖ តាណាៗ ភ្លេចអស់ហើយ ។

ដានី៖ អីចឹងពេលមីងមកពួកគាត់នៅឡើយទេ បានក្រោយមកបានគេយកទៅ?

វុំ៖ ចាំ!

ដានី៖ ប៉ុន្មានខែទៅបានគេយកទៅ?

វុំ៖ កាលហ្នឹងដូចស្ទូងហើយ ដល់ខែច្រូតហើយ ប្រមូលផលហើយហ្នឹង ។

ដានី៖ យាយថែម គាត់មកហើយ?

វុំ៖ ចាំ?

ដានី៖ យាយថែម គាត់មកនៅ?

វុំ៖ យាយថែម មកដំបូងមកនៅតំបន់៤ នៅនិមិត្ត គាត់មកដល់គាត់នៅហ្នឹងមុន ។

ដានី៖ មកណា?

វុំ៖ មកនៅនិមិត្ត ។

ដានី៖ និមិត្តនៅណា?

វុំ៖ អត់ស្គាល់និមិត្ត ប៉ោយប៉ែត?

ដានី៖ គោកនិមិត្តនេះ?

វុំៈ ចាំ!

ដានីៈ ហ្នឹងតំបន់៣គាំ?

វុំៈ តំបន់៣ តំបន់៤ទេហ្នឹង មួយខ្សែហ្នឹង ។ ពូអត់ស្គាល់ទេនៅស្រុកហ្នឹងដែរ?

អ្នកជិតខាងៈ អត់ទេ ខ្ញុំស្គាល់តំបន់៥ តំបន់៣នៅផ្សេងទៀត ។

វុំៈ ចុះតំបន់៤នោះ? តំបន់៤នៅខាងស្ទឹងកែនេះ ។

ដានីៈ អីចឹងយាយថែម គាត់មកហ្នឹង តាហឹង, តាជាល គាត់នៅទេ?

វុំៈ គាត់នៅ ។

ដានីៈ ចុះមកគ្រាន់តាហឹង, តាជាល គាត់ធ្វើប្រធាន គ្រប់គ្រងនៅហ្នឹងធំ?

វុំៈ គាត់នៅធ្វើគ្រប់គ្រងហ្នឹង មិនដឹងម៉េចបានគេយកទៅបាត់ៗមនុស្ស ខ្ញុំអត់ដឹងដែរ ។

ដានីៈ ដល់គេយកទៅបាត់បានយាយថែម គាត់ឡើងមកជំនួស?

វុំៈ អត់ទេ កាលតាហ្នឹងនៅហ្នឹង ក៏យាយថែម មកជាមួយ តាហឹង, តាជាល អីនៅហ្នឹង មកប្រជុំនៅស្វាយ មេៗហ្នឹងប្រជុំជាមួយគ្នាហ្នឹង ប៉ុន្តែមិនដឹងម៉េចបានបាត់ខ្លួន ។

អ្នកជិតខាងៈ តាវ៉ាល់ បាត់ខ្លួនកាលហ្នឹងទាំងអស់ ។

វុំៈ អ្នកណាដឹង បើខ្ញុំមិនដឹងដែរ បើកាលគេយកមេៗខ្ញុំនៅអី ខ្ញុំនៅទន្លេបាសាក់នៅជិតស្រុកយួន គេយកទៅអីចឹងដែរ មិនដឹងគេយកទៅធ្វើម៉េច អ្នកណាដឹង ឃើញដើរទៅ ឃើញបណ្តើរទៅ មិនដឹងគេយកទៅណាៗ យើងម៉េចដឹង យើងហ៊ាន ។

ដានីៈ មីងពេលដែលយួនចូលមកយ៉ាងម៉េចទៅ? ពេលហ្នឹងគេមានយួនជិតចូលមក កាលហ្នឹងយើងដឹងដំណឹង ហើយយើងមានប្រជុំ ដាក់ផែនការយើងត្រូវធ្វើម៉េចៗ?

វុំៈ ប្រជុំ យើងត្រូវដក ប្រយ័ត្នខ្លួន ដឹងតែត្រៀមរត់ហើយ ដឹងយួនចូលដល់ភ្នំពេញមុន ។

ដានីៈ ដឹងដែរ? ដឹងថាយួនចូលដល់ភ្នំពេញដែរ?

វុំៈ ដឹងៗ គេប្រជុំ ។

ដានីៈ ចុះដូចថាសម្ភារៈអី!

វុំៈ ដល់សម្ភារៈគេចែកអាវុធទៅ យើងគ្រប់ដៃ នារី យុវជន ។

ដានីៈ កាលហ្នឹងពេលប្រជុំឲ្យយើងដកខ្លួន ប៉ុន្តែសម្ភារៈនៅតាមសហករណ៍មានស្រូវ មានចាន មានឆ្នាំង?

វុំៈ នៅលើសហករណ៍ នៅលើប្រជាជនទាំងអស់ លែងដឹងហើយ ។

ដានីៈ លែងដឹងហើយ?

រុំៈ យើងដកខ្លួនចេញនៅក្នុងព្រៃ។

ដានីៈ យើងអត់មានលាក់ទុកអីៗ?

រុំៈ ទៅលាក់ទៅណា មួយសាក់កាដូម្នាក់ៗ អង្ករម្នាក់មួយទៃទៅរកណា កាំភ្លើងមួយដើមម្នាក់ ទៅរកស្អី អីចឹងបានចាន ឆ្នាំងអី។

ដានីៈ ហើយពេលហ្នឹងដូចថាយ៉ាងម៉េចទៅ ស្ថានភាពពេលហ្នឹង ពេលដែលមុនដំបូងមីងមកដល់ហ្នឹង ដូចថាយើងសប្បាយ ពេលឃួនថាចូលមកដល់ភ្នំពេញហើយ យើងចាប់ផ្តើមយ៉ាងម៉េច ចាប់ផ្តើមប្រែប្រួលយ៉ាងម៉េចទៀត?

រុំៈ ភ័យ និយាយអត់នេះម៉េច ដេកព្រៃហើយ។

ដានីៈ មីងចេញពីកន្លែងណា? យកអីខ្លះទៅតាមខ្លួន?

រុំៈ ថយទៅដេកព្រៃ ខ្ញុំចេញពីសំរោងមកនៅតាគង់ មកនៅព្រៃតាគង់។

ដានីៈ ព្រៃតាគង់នៅណា?

អ្នកជិតខាងៈ ម៉ាឡៃ?

រុំៈ ចេញពីព្រៃតាគង់មកនៅម៉ក់ហឺន។

ដានីៈ ព្រៃគង់ជិតដល់ម៉ាឡៃហើយហ្នឹង? កន្លែងម៉ក់ហឺនអីហ្នឹង?

រុំៈ ដើរទាំងយប់ទាំងថ្ងៃ ចេញមកពីម៉ាឡៃ ព្រលឹមឡើងយើងដាំបាយហូប លោកចេញហើយបកទៅម៉ក់ហឺនវិញ ដូចឆ្កួតកាលហ្នឹង។

ដានីៈ ទៅវៃម៉ក់ហឺនវិញ។ ចុះមីងពេលដែលយើងមកយើងយកស្អីខ្លះមកតាមខ្លួន?

រុំៈ ចាំ?

ដានីៈ មានស្អីខ្លះដែលប្រមូលពី?

រុំៈ គ្មានស្អីទេ មានតែសំលៀកបំពាក់ អង្រឹងម្នាក់មួយ អង្ករម្នាក់មួយទៃទេ ហើយក្នុងមួយកងឆ្នាំងចាន និយាយរួមម្នាក់មួយយួរៗកើត។

ដានីៈ ចុះដូចរបស់មានតម្លៃ គ្រឿងអលង្កា មីងអត់មានយកទុកដើម្បីការពារខ្លួន?

រុំៈ អ្នកណាទៅស្រវ៉ាតយកអាហ្នឹងយកមកធ្វើស្អី បើចេះយកអាហ្នឹងទៅខុះអី នៅពេញស្វាយហ្នឹងនៅពេញៗឃ្លាំង។

ដានីៈ ពេញៗទាំងឃ្លាំង?

រុំៈ ចាំ!

ដានីៈ មីងអត់យកមក?

រុំៈ យកមកធ្វើអី ។

ដានីៈ ចុះទៅដល់ដីរំយើងមិនចាយ?

រុំៈ ថាទៅសៀមៗយើងអត់ដឹង បើចេះដឹងដូចតារាមអីចឹងនោះ មានកំពូលណាមាសទាំងកាដុង ហើយយើងកំប៉ិកកំប៉ុកនារីៗទៅគិតគួរអីចឹង គេចាស់ចិត្តគំនិតដូចតារាមអីចឹង ។

ដានីៈ អីចឹងមានតែតារាម មួយ?

រុំៈ តារាម គាត់ចេះ ចាស់ចិត្តគំនិត ចាស់ទុំ កាដុងមាសគេ គេដាក់មាសក្នុងកាដុងទឹក កាដុងចិន យើង កាដុងទឹកពេញៗកាដុង គេចាក់ឆ្នៀលយកមក ។

អ្នកជិតខាងៈ គាត់ភ្លេចមួយយប់ ។

រុំៈ គេភ្លេចមួយយប់ ខ្ញុំរើសយកមក គេរត់ចោលហើយ ខ្ញុំសុខចិត្តយកឲ្យគេវិញនេះ ។

ដានីៈ យកឲ្យពីណាវិញ?

រុំៈ យកឲ្យគាត់វិញ ហើយមិនគួរណាគាត់ភ្លេចខ្ញុំ តែឃើញខ្ញុំថ្ងៃណា ក៏គាត់មកលួចក្តិច មកលួច នេះដែរ ខ្ញុំអត់ដឹងយករបស់គេម៉េច ពេញកាដុង ។

ដានីៈ អូ៎! គាត់ភ្លេចកាដុងមាសហ្នឹង ។

រុំៈ គាត់ភ្លេចរត់ទៅបាត់ហើយ ។

ដានីៈ អីចឹងមីងយកឲ្យគាត់ ។

រុំៈ ខ្ញុំយកឲ្យគាត់ គាត់ភ្លេចកូនមួយ កាដុងមួយ ។

ដានីៈ មាសប៉ុន្មានកាដុងដែលគាត់ភ្លេច?

រុំៈ គាត់ស្ពាយទៅខ្លះ គាត់ដាក់ទៃខ្លះ គាត់ដាក់កាដុងខ្លះ ភ្លេចកាដុងចិនឡើងថ្មីជ្រើង នៅចងខ្សែ ក្បាលអង្រឹងហ្នឹង ដល់គ្រាប់ផ្លោងមកគ្រាំង ដល់ខ្ញុំរកមើល ចុមផ្ទះតារាមទៅបាត់អស់ ហើយ ចុះអ្នកណាគេរើកៗនៅហ្នឹង កូនគាត់អាវ៉ាល់មួយហ្នឹង នៅកូនង៉ាក្រហមរលោង គាត់ទៅចោល កូន គិតមនុស្សភ័យ មនុស្សធ្លាប់តស៊ូដែលចេះភ័យរត់ចោលកូន ទៅដល់កូនហ្នឹងវាយំនៅ ភ្វាៗ ខ្ញុំលើកបីកូនហ្នឹង ដល់បីហើយកាដុងហ្នឹងដាក់ក្បាលអង្រឹង វាយោលលើកទៅ ខ្ញុំកាន់យក មក ខ្ញុំអត់ដឹងមាសដែរ តែក្រឡុកទៅអត់លឺក្លេកក្លុកៗ ខ្ញុំយកកូនមកចូលត្រង់សេខ្ញុំប៉ើង មើលឲ្យសុទតែមាស ម៉ែឪមាស គាត់មកវិញលឺសួរមករក អញទៅដល់ភ្នំហើយ ភ្នំថៃហើយ បាត់កូនមួយ សួរម៉ែអាវ៉ាល់ឯណាកូនមួយទៀត ភ្លេចហើយឪអាវ៉ាល់ ឪឯងទៅយកបន្តិចទៅ នៅអង្រឹង ទៅខ្ញុំបីចូលត្រង់សេ ចុះគ្រាប់ផ្លោងវាធ្លាក់កៀនផ្ទះគាត់ឲ្យដឹងៗ បីយកមក ។

អ្នកជិតខាងៈ អាវ៉ាល់ ហ្នឹងរស់ទេ?

វុំៈ អាពាល់ រស់ដល់សព្វថ្ងៃហ្នឹង ។

ដានីៈ គ្រាប់ផ្លោងនៅកន្លែងណាគាត់ក្មេចកូន?

វុំៈ នៅដីថៃហ្នឹង ។

ដានីៈ ដីថៃម្តុំណា?

វុំៈ ដីថៃខាងលិចភ្នំថៃយើងហ្នឹង ។

ដានីៈ គាត់ក្មេចនៅហ្នឹងតែម្តង?

វុំៈ នៅហ្នឹងតែម្តង ។

ដានីៈ ឆ្នាំណាហ្នឹង?

វុំៈ ឆ្នាំប៉ុន្មានទេ ខ្ញុំកាលហ្នឹងមានកូន២ ទើបតែបានកូន២ ឆ្នាំប៉ុន្មានទេ អត់ចាំទេ ។

អ្នកជិតខាងៈ ៨២, ៨១?

ដានីៈ ចុះគាត់អត់មានចែកមាសឲ្យខ្លះទេ មីងរើសឲ្យគាត់ហើយ?

វុំៈ គាត់ឲ្យល៊់រដែរ ឲ្យល៊់រខ្សែដៃហ្នឹង ល៊់រហើយស្អាតណាស់ម៉ែអាឆុនឯងដៃស្ទូតែសាច់ សម ណាស់ ។ សមមិនដឹងយកមាសធ្វើអីខ្ញុំទេ ខ្ញុំចេះចង់បានខ្ញុំយកពីស្វាយមកដែលហើយ ។ ហើយ មានសន្ទឹកគាត់មូលៗដាក់ចូលក្នុងកាដុង ចាក់យកមកខ្សែក អត់មានយក គាត់ក៏មិនថាឲ្យ ក៏ខ្ញុំ មិនចង់បាន មិនដឹងយកធ្វើអី មិនចង់បាន ។

ដានីៈ គាត់អត់មានថាឲ្យ ហើយមីងក៏អត់សុំគាត់?

វុំៈ អត់សុំ ហើយគាត់មិនថាឲ្យទៀត ក៏អត់ ។

ដានីៈ ដល់ឥឡូវគាត់ថាមីងយកបន្តិចខ្លះអត់ទេ?

វុំៈ អត់ ទៅគាត់ធ្វើដើមបើកការស់សាំង លក់ចាប់ហួយ ។

ដានីៈ មីងនៅរាប់អានគាត់ធម្មតា?

វុំៈ នៅជួបគាត់ គាត់សើច គាត់ហៅ គ្រាន់តែថាពូកុំប្រញាប់ក្មេចធាតុដើមពេកៗ អ៊ី មិនបាច់ និយាយរឿងហ្នឹងទេ សុំឡានជិះឲ្យឡានជិះ តែធ្វើម៉េចកុំអង្គុយលើកេមឡានវាអាលាត់ឡាន ។

ដានីៈ មីងមកនៅនេះឆ្នាំណា?

វុំៈ ខ្ញុំឡើងមកនៅនេះឆ្នាំកៅប៉ុន្មានហើយទេ ឆ្នាំប៉ុន្មានទេ ។

អ្នកជិតខាងៈ តាំងពីជំរំសាយធូនោះអេ៊់ ។

វុំៈ យើងមកនៅកាលហ្នឹងអ៊ុនតាក់នៅចូល នៅពេញដីអីស្រុកនោះ មួយរឹកអ៊ុនតាក់នៅហ្នឹង ឆ្នាំ ប៉ុន្មានកាលហ្នឹង?

ដានី៖ អ៊ុនតាក់ចូល៩១-៩២ អ៊ុនតាក់ចូលមក ។

រ៉ុ៖ មិនដឹងកៅប៉ុន្មាន ។

ដានី៖ មុនសមាហរណកម្ម មុនផ្តាច់ខ្លួន មកនៅនេះ?

រ៉ុ៖ ចា៎!

ដានី៖ កាលមុនយើងនៅដីថៃទេ?

រ៉ុ៖ នៅដីថៃ ។

ដានី៖ អត់ដែលនៅដីខ្មែរទេកាលហ្នឹង?

រ៉ុ៖ យី យួននៅច្រើនម៉េចហ៊ាន ដល់យើងរំដោះបាន ឲ្យពួកខ្មែរក្រហមប្រុសៗមកនៅតាមព្រំដែន ហើយយើងដេញទៅបានឆ្ងាយបានយកប្រជាជន កូនចៅមកនៅ ធ្វើផ្ទះ ធ្វើតូបនៅថ្មីៗ ។

ដានី៖ មកនៅនេះមុនដំបូងពីណាគេអ្នកគ្រប់គ្រងតំបន់នេះ?

រ៉ុ៖ គ្រប់គ្រង តារិន ។

ដានី៖ តារិន ណា?

រ៉ុ៖ តារិន នេះយើង ចៅហ្វាយស្រុកក្រឡាញ់ ថ្មពួក ឥឡូវគាត់ស្លាប់បាត់ សុទ្ធកើតអេដស៍ ហើយ ។

អ្នកជិតខាង៖ ចុះតាបៃ?

រ៉ុ៖ តាបៃ នៅតា៎ ។

អ្នកជិតខាង៖ តាបៃ នៅណា?

រ៉ុ៖ គាត់នៅ ។

អ្នកជិតខាង៖ ក្រុមប្រឹក្សាស្រុក?

រ៉ុ៖ គាត់នៅតា៎ ឃើញទៅប្រជុំរៀនបាត់ដំបង មើលក្នុងទូរទស្សន៍ក៏ឃើញមុខគាត់ ។

ដានី៖ ប៉ុន្តែអ្នកគ្រប់គ្រងធំជាងគេនៅ?

រ៉ុ៖ ធំជាងគេ តារម្យ នៅសព្វថ្ងៃហ្នឹងដែរ នៅបារាំងធ្លាក់ ។

ដានី៖ ចុះតាកន?

រ៉ុ៖ តាកន ខាងកងទ័ពធំ ។

ដានី៖ ធំជាងគេនៅកន្លែងហ្នឹង?

រ៉ុ៖ ចា៎ តាកន នៅ៣២ហ្នឹង ។

ដានី៖ ហ្នឹងកន្លែង៣២ដែរ ឬអត់ទេ?

រ៉ុះ ចាំ?

ដានីៈ កាលពីដំនាន់កង់ទ័ព?

រ៉ុះ នេះកង់ទ័ព ៣២នោះដេវ៉ង់ យើងផ្សឹង។

ដានីៈ កង់ទ័ពនេះពីណាគេធំជាងគេ?

រ៉ុះ ចាំ?

ដានីៈ ពីណាដឹកនាំ?

រ៉ុះ នេះខាងតារុំ សព្វថ្ងៃ។

ដានីៈ តារម្យ, តាបៃ ពីរនាក់ហ្នឹង?

រ៉ុះ ចាំ តាម្យ, តាបៃ ដឹកនាំទាហានរាល់ថ្ងៃ។

ដានីៈ ដល់ខាងកំរៀង តាគង់, តាកែវ។

រ៉ុះ តាគង់, តាកែវ។

ដានីៈ ដល់ពេលនេះតាកន។ បាទ មីងយប់ហើយម៉ោងជិត៧ អីចឹងខ្ញុំអរគុណមីងច្រើន ខ្ញុំចង់សួរមីងច្រើនទៀតតែយប់ជ្រៅហើយនេះ បាទ មីងអរគុណច្រើនមីងដែលចំណាយពេលផ្តល់បទសម្ភាសន៍ឲ្យខ្ញុំ។

«ចប់»